ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា
# ២០២៣ - ២០២៨



"អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ,
ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍
ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ
សំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក"

**រៀបចំដោយ**

**គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

**ខែ កក្កដា ឆ្នាំ ២០២៣**

# បុព្វកថា

ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ដែលមានអត្ថន័យជាប្រវត្តិសាស្ត្រ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ព្រមទាំងបានផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈបំផុត តាមរយៈការអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និង យុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់-កាល និង គោលនយោបាយ និង ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ។ ក្នុងនោះ ក្រោមម្លប់សន្តិភាពដែលបាននាំមកដោយ **"គោលនយោបាយឈ្នះ-ឈ្នះ"** កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រមាណ ៧% ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះប្រកបដោយចីរភាព បរិយាបន្ន ភាពធន់នឹងវិបត្តិ និង សមធម៌ ។ ការណ៍នេះបានធ្វើឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥ ហើយត្រូវបានចាត់ទុកជាខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ីនៅឆ្នាំ ២០១៦ ។ ទោះបីការរីករាលដាលនៃជំងឺកូវីដ-១៩ បានរុញច្រានសេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ក្នុងកំណើនអវិជ្ជមាន -៣,១% នៅឆ្នាំ ២០២០ សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងឆាប់រហ័សជាមួយនឹងកំណើន ៣% នៅឆ្នាំ ២០២១ ព្រមទាំងត្រូវបានប៉ាន់ប្រមាណថាមានកំណើន ៥,២% នៅឆ្នាំ ២០២២ និង រំពឹងថានឹងមានកំណើន ៥,៦% នៅឆ្នាំ ២០២៣ ដោយសាររាជរដ្ឋា-ភិបាលបានឆ្លើយតបទាន់ពេល ក្នុងស្មារតីបុរេសកម្ម តាមរយៈការប្រើប្រាស់ **"យុទ្ធសាស្ត្រផ្ការីក"** ដើម្បីធ្វើជាយុទ្ធនាការចាក់វ៉ាក់សាំងបង្កើត **"ភាពស៊ាំសហគមន៍"** ក៏ដូចជាការដាក់ចេញនូវគោលនយោបាយ និង យុទ្ធសាស្ត្រគន្លឹះៗពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដល់ការស្តារ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមក្នុងអំឡុង និង ក្រោយវិបត្តិសុខភាពសកលនេះ ។

សមិទ្ធផលសម្រេចបានខាងលើ បាន និង កំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលឱ្យបន្តបង្កើនកិច្ចខិតខំប្រឹងប្រែង និង សម្លឹងឆ្ពោះទៅមុខ ប្រកបដោយក្តីសង្ឃឹម ភាពជឿជាក់ និង ឆន្ទៈមោះមុត ក្នុងការសម្រេចបាននូវចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ក្រោមបាវចនា **"ក្តាប់មកវិញនូវមោទនភាពជាតិ កសាងជាតិដ៏រស់រវើក"** ។ ក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យទាំងនេះរាជរដ្ឋាភិបាលបាន និង កំពុងយកចិត្តទុកដាក់ខ្ពស់លើការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមកម្ពុជាទាំងមូល ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និង ការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ចនាពេលអនាគត ដោយបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ដែលមានចក្ខុវិស័យ **"កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង ការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ពលរដ្ឋ និង ធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លងប្រក្រតីភាពថ្មី"** ។ ក្របខណ្ឌគោលនយោបាយនេះ ជាមាគ៌ាគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលក្នុងការធ្វើបរិវត្តកម្មឌីជីថលទៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ដែលរួមបញ្ចូលនូវការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីបំពេញបន្ថែមទៅលើគោលនយោបាយដែលគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថល និង យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ សំដៅតម្រង់ទិសដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចថ្មី, លើកកម្ពស់សុខុមាលភាពរបស់អ្នកប្រើប្រាស់នៃសង្គមឆ្លាត ក៏ដូចជាបង្កើនផលិតភាព ពិពិធភាព និង ប្រសិទ្ធភាពនៃវិស័យផ្សេងទៀត តាមរយៈការជួយលើកកម្ពស់ការទទួលបាន និង ការប្រើប្រាស់សេវា និង ផលិតផលហិរញ្ញវត្ថុប្រកបដោយគុណភាព, ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រមទាំងការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍ឧស្សាហកម្មហិរញ្ញវត្ថុ ។

ឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ក៏ដូចជាស្របតាមបទពិសោធ និង និន្នាការនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងតំបន់ និង ពិភពលោក ដែលមានសមានគតិភាពជាមួយនឹងស្ថានភាពកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **"គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"** ដែលមានចក្ខុវិស័យរយៈពេលវែង **"អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក"** ។ ក្នុងន័យនេះ ការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ ត្រូវផ្សារភ្ជាប់ជាមួយនឹងការគ្រប់គ្រង និង ការកាត់បន្ថយហានិភ័យឱ្យស្ថិតក្នុងកម្រិតអប្បបរមា ។ ក្នុងដំណាក់កាលប្រែប្រួលថ្មីនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកម្ពុជា ក្នុងរយៈពេលមធ្យម គោលនយោបាយនេះនឹងចូលរួមគាំទ្រ **"កម្មវិធីនយោបាយ"** របស់រាជរដ្ឋាភិបាលក្នុងរយៈពេល ៥ ឆ្នាំទៅមុខ សម្រាប់ដំណើរផ្លាស់ប្តូរស៊ីជម្រៅរបស់កម្ពុជាឈានទៅសម្រេចបាននូវ **"ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០"** ។ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តគោលនយោបាយនេះ ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ត្រូវចូលរួមឱ្យបានពេញលេញ សហការគ្នាជាធ្លុងមួយ ដោយមានការសម្របសម្រួល និង ការពង្រឹងកិច្ចសហការ និង កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ប្រកបដោយស្មារតីបុរេសកម្ម និង អន្តរសកម្មបំផុត សហថាមពល និង សហការទទួលខុសត្រូវខ្ពស់ក្នុងស្មារតីអភិក្រមរដ្ឋាភិបាលទាំងមូល និង ជវភាពនៃប្រព័ន្ធតួអង្គតែមួយ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** ដែលបានដឹកនាំរៀបចំសេចក្តីព្រាងគោលនយោបាយរហូតសម្រេចបាននូវសមិទ្ធផលជាគោលនយោបាយនេះឡើង ។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាប្រធាន អនុប្រធាន សមាជិក និង សមាជិកានៃក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយនេះ និង ក្រុមការងារបច្ចេកទេសជាសេនាធិការ ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមសហការរៀបចំ យ៉ាងសកម្ម និង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ថ្ងៃសុក្រ ៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## អារម្ភកថា

ក្រោមការដឹកនាំដ៏វៃឆ្លាសប្រកបដោយគតិបណ្ឌិតដ៏ឧត្តមរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមហារដ្ឋបុរស និង អគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃសន្តិភាពរូបនីយកម្មសង្គម, ស្ថិរភាពរូបនីយកម្មនយោបាយ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ស្ថាបនកម្មនីតិរដ្ឋទំនើប, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនគួរជាទីមោទនៈក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ដើម្បីជាតិ និង ប្រជាជន ផ្អែកលើគុណតម្លៃរដ្ឋធម្មនុញ្ញ ។ ផ្អែកលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបាន និង កំពុងដាក់ចេញនូវ **"របៀបវារៈគោលនយោបាយ"** របស់ខ្លួន ប្រកបដោយមហិច្ឆតាសម្រាប់អនុវត្តកម្មវិធីនយោបាយក្នុងការកសាងមូលដ្ឋានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០ និង ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ។ ក្នុងនោះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** សម្រាប់ជាមគ្គុទេសក៍ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជារស់រវើក ដែលការណ៍នេះនឹងរួមចំណែកដល់ការកសាង **"ម៉ូដែលកំណើនថ្មី"** បំពេញបន្ថែមលើម៉ូដែលកំណើនចាស់ និង លើកកម្ពស់សុខុមាលភាពសង្គមឆ្លាត តាមរយៈការកសាងមូលដ្ឋានគ្រឹះឌីជីថល ការចាប់យកឌីជីថល និង ការធ្វើបរិវត្តកម្មឌីជីថល ។

ក្នុងន័យនេះ ដើម្បីចាប់យកកាលានុវត្តភាព និង សក្ដានុពលដ៏ធំធេងនៃបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ ដែលឆ្លើយតបទៅនឹងការផ្លាស់ប្ដូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត, រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ក្នុងការដឹកនាំរៀបចំ **"គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"** ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និង និន្នាការសកលភាវូបនីយកម្ម និង តំបន់ភាវូបនីយកម្មនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ទោះបីជាគោលនយោបាយនេះត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ៥ ឆ្នាំ គោលនយោបាយនេះមានចក្ខុវិស័យរយៈពេលវែងក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្ដល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក ដោយឈរលើគោលការណ៍ធំៗចំនួន ៣ គឺ (១)-ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, (២)-ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង (៣)-ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ។ បម្រើឱ្យចក្ខុវិស័យរយៈពេលវែងនេះ គោលនយោបាយនេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ, ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នកប្រើប្រាស់ ក្នុងយុគសម័យឌីជីថល តាមរយៈការកំណត់នូវគោលដៅចម្បង ដែលជាផ្នែកទាំង ៤ នៃដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា គឺ (១)-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ដែលតំណាងដោយ **"ដី"**, (២)-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ដែលតំណាងដោយ **"ឫស"**, (៣)-ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដែលតំណាងដោយ **"ដើម"** និង (៤)-ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលតំណាងដោយ **"មែក"** ។ ស្របតាមគោលដៅចម្បងទាំង ៤ នេះ វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុទាំងអស់ត្រូវបានរៀបចំឡើងក្នុងស្មារតីនៃការធ្វើសមាហរណកម្ម និង ការធ្វើសុខដុមនីយកម្មវិធានការគោលនយោបាយក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។ ការអនុវត្តវិធានការគោលនយោបាយទាំងនេះ ត្រូវគោរពតាមអភិក្រមចំនួន ៣

គឺ (១)-ការចាប់យក, (២)-ការកែសម្រួល និង (៣)-ការធ្វើនវានុវត្តន៍បន្ថែម ក្នុងគោលគំនិត **"ទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង កាត់បន្ថយហានិភ័យឱ្យស្ថិតក្នុងកម្រិតអប្បបរមា"** ដោយឈរលើគោលដំហរ **"ចៃទាំដើមឈើឱ្យលូតលាស់ល្អ និង អាស្រ័យផលបាន ត្រូវការដីមានជីជាតិដែលអំណោយផលដល់ការស្រូបយករបស់ឬស, ឬសមាំ និង ច្រើនដែលអាចស្រូបយកជីជាតិបានល្អសម្រាប់ទ្រទ្រង់ដល់ភាពរឹងមាំរបស់ដើម, ដើមរឹងមាំសម្រាប់ទ្រទ្រង់ដល់ការលូតលាស់ល្អរបស់មែក និង មែកបែកសាខាប្រកបដោយផ្លែផ្កាច្រើន ដែលអាចអាស្រ័យផលបាន"** ។ ដើម្បីឱ្យការអនុវត្តគោល-នយោបាយនេះសម្រេចបាននូវភាពជោគជ័យ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមឱ្យបានពេញលេញ ប្រកបដោយស្មារតីបុរេសកម្ម អន្តរសកម្ម សហថាមពល ម្ចាស់ការ សហការទទួលខុសត្រូវខ្ពស់ និង សិនិទ្ធភាព ព្រមទាំងប្រតិបត្តិតាមឱ្យបានខ្ជាប់ខ្ជួននូវគុណតម្លៃស្ថាប័ន និង បំពេញកិច្ចការស្របតាមអភិក្រមរដ្ឋាភិបាលទាំងមូល និង ជវភាពនៃប្រព័ន្ធតួអង្គតែមួយ ។

ជាទីបញ្ចប់ ក្នុងនាមប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល និង រូបខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមហាបុរសរដ្ឋ និង អគ្គមគ្គុទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈនយោបាយមុតស្រួចលើការងារកែទម្រង់ និង ការដឹកនាំការអភិវឌ្ឍ និង ការផ្លាស់ប្តូរមុខមាត់របស់កម្ពុជាឥតឈប់ឈរក្នុងចក្ខុវិស័យវែងឆ្ងាយ ។ ខ្ញុំក៏សូមអរគុណចំពោះក្រសួង-ស្ថាប័នទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និង បានផ្តល់កិច្ចសហការជាមួយនឹងគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល រហូតបានបញ្ចប់គោលនយោបាយនេះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងាររៀបចំគោលនយោបាយ និង ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ព្រមទាំងប្រធាន អនុប្រធាន សមាជិក និង សមាជិកានៃក្រុមការងារបច្ចេកទេសជាសេនាធិការទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំឯកសារនេះរហូតសម្រេចបានជាស្ពាពរ ។

ថ្ងៃ ចន្ទ ១៥កើត ខែ បឋមាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និង ជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

**បុព្វកថា** .......... i
**អារម្ភកថា** .......... iii
**បញ្ជីពាក្យកាត់** .......... vii
**ខ្លឹមសារសង្ខេប** .......... ix
**១. សេចក្តីផ្តើម** .......... ១
**២. ការអភិវឌ្ឍ និង ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ** .......... ៣
២.១. ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ .......... ៣
២.២. បច្ច័យវិជ្ជមាន និង ហានិភ័យនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ .......... ៤
២.៣. ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា .......... ៥
**៣. ក្របខណ្ឌគោលនយោបាយ** .......... ១០
៣.១. ចក្ខុវិស័យ គោលបំណង និង គោលដៅ .......... ១០
៣.២. គោលការណ៍ និង អភិក្រម .......... ១៣
៣.៣. វិធានការគោលនយោបាយ .......... ១៤
៣.៣.១. ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល .......... ១៤
៣.៣.២. ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ .......... ១៦
៣.៣.៣. ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ .......... ១៧
៣.៣.៤. ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ .......... ១៨
**៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ** .......... ២០
**៥. សន្និដ្ឋាន** .......... ២១
**ឧបសម្ព័ន្ធ ១. តារាងវិធានការគោលនយោបាយ** .......... ២៣
**ឧបសម្ព័ន្ធ ២. សន្ទានុក្រម** .......... ៣៥

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADBI | វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank Institute) |
| AI | បញ្ញាសិប្បនិម្មិត (Artificial Intelligence) |
| APIs | សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interfaces) |
| CamDigiKey | ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (Cambodia Digital Key) |
| CamDL | ថ្នាលបច្ចេកវិទ្យាប្លុកឆេនកម្ពុជា (Cambodia Distributed Ledger) |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange) |
| CCAF | មជ្ឈមណ្ឌលខេមប្រ៊ីជសម្រាប់ហិរញ្ញវត្ថុជំនួស (Cambridge Centre for Alternative Finance) |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វិច (Cambodian Shared Switch) |
| dApp | កម្មវិធីវិមជ្ឈការ (Decentralized Application) |
| FinTech | បច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology) |
| GPCA | សមាគមមូលធនឯកជនសកល (Global Private Capital Association) |
| ML | ម៉ាស៊ីនស្វ័យសិក្សា (Machine Learning) |
| MSMEs | សហគ្រាសធុនមីក្រូ តូច និង មធ្យម (Micro, Small, and Medium Enterprises) |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) |
| NLP | បច្ចេកវិទ្យាប្រព្រឹត្តិកម្មភាសាធម្មជាតិ (Natural Language Processing) |
| OBS | ប្រព័ន្ធធនាគារអនឡាញ (Online Banking System) |
| P2P Financing | ហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល (Peer-to-peer Financing) |
| P2P Lending | ការផ្តល់ប្រាក់កម្ចីពីបុគ្គលទៅបុគ្គល (Peer-to-peer Lending) |
| RegTech | បច្ចេកវិទ្យានិយ័តកម្ម (Regulatory Technology) |
| SupTech | បច្ចេកវិទ្យាត្រួតពិនិត្យ (Supervisory Technology) |

# ខ្លឹមសារសង្ខេប

វិស័យហិរញ្ញវត្ថុជាវិស័យមួយក្នុងចំណោមវិស័យជាច្រើន ដែលទទួលរងឥទ្ធិពលយ៉ាងខ្លាំង ទាំងវិជ្ជមាន និង អវិជ្ជមាន ពីភាពរីកចម្រើននៃបច្ចេកវិទ្យា ជាពិសេសក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនៃដំណាក់កាលដែលសកលលោក បាន និង កំពុងទទួលរងនូវឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មទី ៤ ។ បច្ចេកវិទ្យាដែលបាន និង កំពុងធ្វើបរិវត្តកម្មរបៀបនៃការធ្វើធុរកិច្ច និង ការផ្តល់សេវាហិរញ្ញវត្ថុប្រពៃណី ធ្វើឱ្យលេចឡើងនូវ "**បច្ចេកវិទ្យាហិរញ្ញវត្ថុ**" ។ បច្ចេកវិទ្យាថ្មីៗជាច្រើនដែលរួមមានដូចជា បញ្ញាសិប្បនិម្មិត, បច្ចេកវិទ្យាវិភាគទិន្នន័យ, បច្ចេកវិទ្យាក្លោដ និង បច្ចេកវិទ្យាប្លុកឆេន ដែលត្រូវបានប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុ បាន និង កំពុងពន្លឿនការអភិវឌ្ឍ ឬ ការធ្វើបរិវត្តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងល្បឿនលឿនហួសពីការរំពឹងទុក ។ បច្ចេកវិទ្យាហិរញ្ញវត្ថុបានជួយសម្រួលដល់ការរស់នៅប្រចាំថ្ងៃរបស់អ្នកប្រើប្រាស់, ការប្រកបអាជីវកម្ម ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមទាំងមូល ជាពិសេសក្នុងអំឡុង និង ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ។ ដោយមើលឃើញពីកាលានុវត្តភាព និង សក្តានុពលដ៏ធំធេងនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា, រាជរដ្ឋាភិបាល បាន និង កំពុងយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនទីមគ្គទេសក៍ពាក់ព័ន្ធ ។ ទោះបីជាយ៉ាងនេះក្តី, កម្ពុជានៅមិនទាន់បានកំណត់ក្របខណ្ឌរួម និង យន្តការសម្របសម្រួល និង ជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅឡើយ ។ បន្ថែមលើនេះ, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះ និង ភាពពុំច្បាស់លាស់នៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត, កង្វះសមាមាត្រភាពក្នុងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត និង កង្វះថ្នាលឌីជីថលគ្រឹះជាដើម ។

ក្នុងន័យនេះ, ដើម្បីកំណត់ក្របខណ្ឌរួម ក៏ដូចជាដោះស្រាយបញ្ហាប្រឈមខាងលើ, រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចរៀបចំ និង ដាក់ចេញនូវ "**គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**" ។ គោលនយោបាយនេះមានគោលបំណង "**អភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើកតាមរយៈការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ, ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នកប្រើប្រាស់ ក្នុងយុគសម័យឌីជីថល**" ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ, ការអនុវត្តគោលនយោបាយនេះត្រូវផ្តោតលើអភិក្រមចំនួន ៣ គឺ (១)-**ការចាប់យក**, (២)-**ការកែសម្រួល និង** (៣)-**ការធ្វើនវានុវត្តន៍បន្ថែម** ដោយជារួមឈរលើគោលគំនិត "**ទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង កាត់បន្ថយហានិភ័យឱ្យស្ថិតក្នុងកម្រិតអប្បបរមា**" ។

វិធានការគោលនយោបាយសរុបទាំង **៥២** ដែលបានដាក់ចេញ និង បែងចែកទៅតាមគោលដៅនីមួយៗ

ត្រូវសម្រេចឱ្យបានក្នុងរយៈពេល ៥ ឆ្នាំ ។ ក្នុងនោះ, ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល មានចំនួន **១៩** វិធានការ, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ មានចំនួន **១២** វិធានការ, ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ មានចំនួន **១២** វិធានការ និង ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ មានចំនួន **៩** វិធានការ ។

ដើម្បីជំរុញការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញ ឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ គោលបំណង និង គោលដៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការរៀបចំក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល, តាមដាន និង វាយតម្លៃ ត្រូវស្ថិតនៅក្រោមយន្តការស្ថាប័នដែលមានស្រាប់ គឺ ធនាគារជាតិនៃកម្ពុជា, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ដោយឡែក, គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល នឹងត្រូវទទួលបន្ទុកសិក្សាស្រាវជ្រាវលើសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុណាដែលកំពុងលេចឡើងថ្មីៗ ហើយមិនស្ថិតនៅក្រោមសមត្ថកិច្ចនៃស្ថាប័នណាមួយជាក់លាក់ សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យ និង ការសម្របសម្រួល មុននឹងប្រគល់ជូនដល់ស្ថាប័នដែលត្រូវសម្រេចថាជាតួអង្គអនុវត្ត ។ បន្ថែមលើនេះ, ក្រៅពីការអនុវត្តវិធានការគោលនយោបាយ, គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ក៏ត្រូវបំពេញភារកិច្ចដឹកនាំសម្របសម្រួល, ពិនិត្យ, តាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយនេះផងដែរ ។

គោលនយោបាយនេះ ត្រូវបានចាត់ទុកជា **"ឯកសាររស់"** ដែលជាកម្មវត្ថុនៃការកែសម្រួលបន្ថែមនាពេលអនាគត អនុលោមតាមឧត្តមានុវត្តន៍ និង និន្នាការនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍តំបន់ និង សកល ជាពិសេសការលេចឡើងនូវបច្ចេកវិទ្យាថ្មីៗក្នុងការធ្វើបរិវត្តកម្មក្នុងវិស័យហិរញ្ញវត្ថុ ក៏ដូចជាស្ថានភាពជាក់ស្តែងនៅកម្ពុជា ។

# ១. សេចក្តីផ្តើម

ស្របតាមនិន្នាការតំបន់ និង សកល, បរិវត្តកម្មឌីជីថលត្រូវបានចាត់ទុកជាកម្លាំងចលករដ៏ចម្បងក្នុងការជំរុញសម្ទុះកំណើនសេដ្ឋកិច្ចឌីជីថលក្នុងសតវត្សរ៍ទី ២១ តាមរយៈការជំរុញការចាប់យក និងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីភាពរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល ។ ក្នុងអំឡុងពេលវិបត្តិសកលនៃជំងឺកូវីដ-១៩, បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីកាន់តែសំខាន់ក្នុងការផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាព និង ជួយសម្រួលដល់ការរក្សាបាននូវប្រក្រតីភាពនៃសកម្មភាព និង ប្រតិបត្តិការរបស់វិស័យសាធារណៈ, វិស័យឯកជន និង អ្នកប្រើប្រាស់ ។

**"បច្ចេកវិទ្យាហិរញ្ញវត្ថុ"** ( Financial Technology – FinTech ) កើតចេញពីការផ្សំពាក្យចំនួន ២ គឺ **"បច្ចេកវិទ្យា"** និង **"ហិរញ្ញវត្ថុ"** ។ ទោះបីមិនទាន់មាននិយមន័យប្រើប្រាស់ជារួម, យោងតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, កន្សោមពាក្យ **"បច្ចេកវិទ្យាហិរញ្ញវត្ថុ"** សំដៅដល់បច្ចេកវិទ្យា និង នវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បង្កើតឡើងដើម្បីឱ្យមានការប្រើប្រាស់ ផ្តល់ និង ទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយ ប្រកបដោយបរិយាបន្នកម្ម ។

ទោះបីជាកន្សោមពាក្យ **"បច្ចេកវិទ្យាហិរញ្ញវត្ថុ"** ទើបតែត្រូវបានគេស្គាល់ និង ដឹងឮទូលំទូលាយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី, បច្ចេកវិទ្យាហិរញ្ញវត្ថុ មានសាវតារតាំងពីឆ្នាំ ១៨៦៦ មកម្ល៉េះ និង មានការវិវឌ្ឍជាច្រើនដំណាក់កាលមកដល់បច្ចុប្បន្ន ។ នៅក្នុងដំណាក់កាលដំបូង, បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រដល់ដំណើរការផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ពោលគឺមិនបានយកមកប្រើប្រាស់សម្រាប់ការផ្តល់សេវាដល់អ្នកប្រើប្រាស់នោះទេ ។ ប៉ុន្តែ, នៅក្នុងដំណាក់កាលបន្តបន្ទាប់, បច្ចេកវិទ្យាហិរញ្ញវត្ថុបានពង្រីកវិសាលភាពនៃមុខងាររបស់ខ្លួន តាមរយៈការផ្តល់សេវា និង ផលិតផលហិរញ្ញវត្ថុ ដល់អ្នកប្រើប្រាស់ឱ្យកាន់តែប្រសើរឡើង ។ បច្ចេកវិទ្យាហិរញ្ញវត្ថុ មានសារៈសំខាន់មិនអាចខ្វះបានក្នុងការជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការបង្ខិតសេវា និង ផលិតផលហិរញ្ញវត្ថុឱ្យទៅដល់ប្រជាជនគ្រប់រំដែននៅគ្រប់ទីកន្លែង ព្រមទាំងកាត់បន្ថយថ្លៃសេវា និង បង្កើតឱ្យមានភាពងាយស្រួលដល់ការប្រើប្រាស់សេវាហិរញ្ញវត្ថុជាដើម ។ ជាងនេះទៅទៀត, បច្ចេកវិទ្យាហិរញ្ញវត្ថុក៏អាចចូលរួមរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុផងដែរ តាមរយៈការបង្កើនវិមជ្ឈការ និង ពិពិធកម្មហិរញ្ញវត្ថុ, ការលើកកម្ពស់ប្រសិទ្ធភាពនៃសេវាហិរញ្ញវត្ថុ, ការបង្កើនតម្លាភាពហិរញ្ញវត្ថុ និង ការពង្រឹងអធិបតេយ្យភាពក្នុងវិស័យហិរញ្ញវត្ថុ ។

ការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុមានសម្ទុះគួរឱ្យកត់សម្គាល់ ដែលការណ៍នេះអាចឃើញច្បាស់តាមរយៈការកើនឡើងនៃការប្រើប្រាស់សេវាធនាគារចល័ត ( Mobile Banking ) សម្រាប់ការទូទាត់សងប្រាក់ឌីជីថល ជាដើម ។ ក្នុងអំឡុងពេលវិបត្តិសកលនៃជំងឺកូវីដ-១៩, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ មានសម្ទុះគួរឱ្យកត់សម្គាល់ ជាពិសេសការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, ការដាក់ឱ្យដំណើរការ និង ប្រើប្រាស់ប្រព័ន្ធបាគង ( Bakong ) និង ស្តង់ដាខេអេចឃ្យូអរ ( KHQR )

ព្រមទាំងការប្រើប្រាស់យ៉ាងទូលំទូលាយនូវសេវាធនាគារចល័តផ្សេងទៀត ។ ជាមួយគ្នានេះ, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារក៏បាន និង កំពុងបោះជំហានក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ជាពិសេសកំណើនក្នុងវិស័យធានារ៉ាប់រង និង វិស័យមូលបត្រ ។ សម្ទុះនៃការអភិវឌ្ឍទាំងនេះបាន និង កំពុងក្លាយជាកាលានុវត្តភាពថ្មី ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ឌីជីថល ព្រមទាំងបង្កើតធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Startups) ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបាននូវការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសការទូទាត់សងប្រាក់ឌីជីថល ។ ទោះបីជាយ៉ាងនេះក្តី, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា នៅមានបញ្ហាប្រឈមចម្បង រួមមាន (១)-កង្វះ និង ភាពពុំច្បាស់លាស់នៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន, (២)-កង្វះសមាមាត្រភាពក្នុងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត, (៣)-កង្វះថ្នាលឌីជីថលគ្រឹះ, (៤)-កង្វះនវានុវត្តន៍ក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ និង (៥)-កង្វះបុគ្គលមានទេពកោសល្យ ឬ មូលធនមនុស្សបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ភាពមានកម្រិតនៃអក្ខរកម្មឌីជីថល (Digital Literacy) និង អក្ខរកម្មហិរញ្ញវត្ថុ (Financial Literacy) របស់អ្នកប្រើប្រាស់ ។ ការរីកចម្រើននៃសេវា ឬ ផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុតែមួយមុខ គឺមិនគ្រប់គ្រាន់ទេ ក្នុងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ហេតុនេះ, ការធ្វើពិពិធកម្មសេវា និង ផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុដទៃទៀតនៅក្នុងទីផ្សារ មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ សេវា និង ផលិតផលទាំងនោះមានដូចជា ការផ្តល់ប្រាក់កម្ចីពីបុគ្គលទៅបុគ្គល (Peer-to-peer Lending – P2P Lending), ការសន្សំប្រាក់ឌីជីថល, សេវាធនាគារឌីជីថល, ហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល (Peer-to-peer Financing – P2P Financing), អាជីវកម្មក្រោដហ្វាន់ឌីង (Crowdfunding) និងការជួញដូរវិក្កយបត្រ (Invoice Trading) ជាដើម ។ សេវា និង ផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុទាំងនេះ ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយបំពេញតម្រូវការនៃការរស់នៅប្រចាំថ្ងៃ និង ការធ្វើសុវុឌ្ឍិកម្មសេវាហិរញ្ញវត្ថុដល់សាធារណជនទូទៅ, ធុរកិច្ចថ្មី និង សហគ្រាសធុនមីក្រូ តូច និង មធ្យម (Micro, Small, and Medium Enterprises – MSMEs) ។

ក្នុងចរន្តសកលភាវូបនីយកម្ម និង តំបន់ភាវូបនីយកម្មឌីជីថល ក៏ដូចជាចលនាបរិវត្តកម្មឌីជីថល, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជារបៀបវារៈគោលនយោបាយអាទិភាពមួយសម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និង ការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត ។ ជាមួយគ្នានេះដែរ, សម្រាប់កម្ពុជា, រាជរដ្ឋាភិបាល បានដាក់ចេញឱ្យអនុវត្តនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលក្នុងនោះបច្ចេកវិទ្យាហិរញ្ញវត្ថុក៏ត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រអាទិភាពមួយនៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលទាមទារឱ្យមានការគិតគូរបន្ថែម ។ ឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ក៏ដូចជាដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ, រាជរដ្ឋាភិបាលបានដាក់ចេញនូវ **"គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យា**

**ហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨**" ដោយកំណត់នូវចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា គឺ "**អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក**" ។

## ២. ការអភិវឌ្ឍ និង ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ

### ២.១. ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

ជាការវាយតម្លៃទូទៅ, កម្រិតនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍តំបន់ និង សកល មានការប្រែប្រួល និង លក្ខណៈខុសៗគ្នា ។ យោងតាមរបាយការណ៍ស្តីពី "ការធ្វើចំណាត់ថ្នាក់សន្ទស្សន៍បច្ចេកវិទ្យាហិរញ្ញវត្ថុសកល" ឆ្នាំ ២០២១, ប្រទេសចំនួន ៥ ដែលមានការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុខ្លាំងក្នុងសកល-លោក គឺ សហរដ្ឋអាម៉េរិក, ចក្រភពអង់គ្លេស, អ៊ីស្រាអែល, សិង្ហបុរី និង ស្វីស ។ យោងតាមការសិក្សាមួយរបស់មជ្ឈមណ្ឌលខេមប្រ៊ីជសម្រាប់ហិរញ្ញវត្ថុជំនួស (Cambridge Centre for Alternative Finance – CCAF), វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank Institute – ADBI) និង ហ្វីនតិចស្បេស (FinTech Space) ដែលបានធ្វើឡើងនៅឆ្នាំ ២០១៩ ជាមួយនឹងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការក្នុងតំបន់អាស៊ាន, ប្រទេសសិង្ហបុរី និង ឥណ្ឌូណេស៊ី ជាប្រទេសដែលមានក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុច្រើនជាងគេរហូតដល់ ៥០% ។ ចំណែកប្រទេសដែលមានចំនួនក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការក្នុងតំបន់បន្ទាប់ពីប្រទេសសិង្ហបុរី និង ឥណ្ឌូណេស៊ី គឺប្រទេសម៉ាឡេស៊ី (១១%), ថៃ (១០%), ហ្វីលីពីន (៧%), កម្ពុជា (៤%), វៀតណាម (៣%) និង មីយ៉ាន់ម៉ា (១%) ។ ចំណែកក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុចំនួន ១៨% ទៀត ជាក្រុមហ៊ុនដែលមកពីប្រទេសផ្សេងដែលមិនស្ថិតក្នុងតំបន់អាស៊ាន ។ ទោះបីជាសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុមានការកើនឡើងទូទាំងសកល-លោក និង តំបន់ក៏ពិតមែន, បើយោងតាមរបាយការណ៍របស់ហ្គូហ្គល (Google), តាម៉ាសេក (Tamasek) និង បេនអេនខមផេននី (Bain & Company) ឆ្នាំ ២០២២, សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមានភាពលេចធ្លោក្នុងតំបន់អាស៊ានមានចំនួន ៥ គឺ (១)-ការទូទាត់សងប្រាក់ឌីជីថល, (២)-ការវិនិយោគ, (៣)-ការផ្តល់ប្រាក់កម្ចីឌីជីថល, (៤)-ការផ្ទេរប្រាក់ និង (៥)-បច្ចេកវិទ្យាធានារ៉ាប់រង ។ បច្ចេកវិទ្យាហិរញ្ញវត្ថុបាន និង កំពុងទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីវិនិយោគិនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ យោងតាមទិន្នន័យរបស់សមាគមមូលធនឯកជនសកល (Global Private Capital Association – GPCA), ទំហំវិនិយោគលើបច្ចេកវិទ្យាក្នុងតំបន់អាស៊ានមានការកើនឡើងពី ៤,២ ប៊ីលានដុល្លារអាម៉េរិកនៅឆ្នាំ ២០១៧ ដល់ ១២,៩ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ ២០២២ ដែលក្នុងនោះ ទំហំវិនិយោគលើបច្ចេកវិទ្យាហិរញ្ញវត្ថុបានកើនឡើងយ៉ាងគំហុករហូតដល់ ៤,១ ប៊ីលានដុល្លារអាម៉េរិក ។

## ២.២. បច្ច័យវិជ្ជមាន និង ហានិភ័យនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ

តាមបទពិសោធ និង ឧត្តមានុវត្តន៍អន្តរជាតិ, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុផ្តល់បច្ច័យវិជ្ជមានជាច្រើន ដល់ (១)- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, (២)- ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង (៣)- ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ។ ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, បច្ចេកវិទ្យាហិរញ្ញវត្ថុអាចធ្វើប្រជាធិបតេយ្យកម្មការទទួលបាននូវសេវាហិរញ្ញវត្ថុ, ជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុ និង លើកកម្ពស់គុណភាពនៃសេវាហិរញ្ញវត្ថុកាន់តែប្រសើរ ជាមួយនឹងការកាត់បន្ថយការចំណាយ និង ពេលវេលា ។ យោងតាមកាសែត "ដឹហ្វីនតិចថាម" (The FinTech Times) ចុះផ្សាយ ឆ្នាំ ២០២១, មនុស្សពេញវ័យចំនួន ១,២ ប៊ីលាននាក់ ដែលមិនមានគណនីធនាគារពីមុនមក ទទួលបាននូវសេវាហិរញ្ញវត្ថុ ។ ការណ៍នេះ បាននាំឱ្យចំនួនប្រជាជនដែលមិនមានគណនីធនាគារថយចុះចំនួន ៣៥% ។ ការកើនឡើងនៃការទទួលបាននូវសេវាហិរញ្ញវត្ថុនេះមួយផ្នែកគឺដោយសារតែការកើនឡើងនៃគណនីរូបិយវត្ថុចល័ត (Mobile Money Accounts) ។ ក្នុងការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, បច្ចេកវិទ្យាហិរញ្ញវត្ថុជំរុញវិមជ្ឈការ និង ការធ្វើពិពិធកម្មហិរញ្ញវត្ថុ, ការលើកកម្ពស់តម្លាភាព, ប្រសិទ្ធភាព និង សក្តិសិទ្ធិភាពនៃសេវាហិរញ្ញវត្ថុ និង ការពង្រឹងអធិបតេយ្យភាពក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រមួយចំនួន ។ ក្នុងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ, បច្ចេកវិទ្យាហិរញ្ញវត្ថុទាមទារនូវការអភិវឌ្ឍបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Regulatory Sandbox), ការធ្វើពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការជំរុញនវានុវត្តន៍ ឬ ធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ ឬ មន្ទីរពិសោធន៍នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ និង ការផ្តួចផ្តើមគំនិតនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងទៀត ។

យ៉ាងណាមិញ, បច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏អាចបង្កហានិភ័យផងដែរ ដល់ស្ថិរភាពវិស័យសេដ្ឋកិច្ច ក៏ដូចជាអធិបតេយ្យភាពក្នុងវិស័យហិរញ្ញវត្ថុ និង សង្គម ។ ក្នុងនោះ, បច្ចេកវិទ្យាហិរញ្ញវត្ថុ អាចបង្កហានិភ័យដល់វិស័យសេដ្ឋកិច្ចតាមរយៈកត្តាមួយចំនួន រួមមានដូចជា ការគ្របដណ្តប់ទីផ្សារមួយភាគធំដោយក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនតូច, ការកើនឡើងនៃការប្រើប្រាស់ទ្រព្យឌីជីថល (Digital Asset) និង ការកើនឡើងជាគំហុកនៃគ្រឹះស្ថានផ្តល់ឥណទាន, ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និង សេវា ឬ ផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុដទៃទៀត ដែលមិនមែនជាគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។ បច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏អាចបង្កហានិភ័យដល់អធិបតេយ្យភាពក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសជុំវិញការទូទាត់សងប្រាក់ឌីជីថល ។ ឧទាហរណ៍, ប្រសិនបើប្រទេសមួយពឹងផ្អែកស្ទើរតែទាំងស្រុងលើក្រុមហ៊ុនអន្តរជាតិ ជាពិសេសក្រុមហ៊ុនបច្ចេក-វិទ្យាយក្ស សម្រាប់ការផ្តល់សេវាទូទាត់សងប្រាក់ឌីជីថល, អធិបតេយ្យភាពក្នុងវិស័យហិរញ្ញវត្ថុរបស់ប្រទេសនោះនឹងអាចទទួលរងនូវការគំរាមកំហែង ។ ចំពោះហានិភ័យដល់សង្គម, បច្ចេកវិទ្យាហិរញ្ញវត្ថុអាចនាំឱ្យមានកង្វះបរិយាបន្នហិរញ្ញវត្ថុ តាមរយៈភាពលំអៀងនៃក្បួនដោះស្រាយ (Algorithmic Bias) និង ការផ្តល់ប្រាក់កម្ចីបែបប្រថុយប្រថាន (Predatory Lending Practices) ដែលការណ៍នេះនឹងនាំឱ្យមានផលអវិជ្ជមានដល់ប្រជាជនដែលងាយរងគ្រោះ ដូចជា ស្ត្រី, ប្រជាជនក្រីក្រ, មនុស្សចាស់ និង ប្រជាជនរស់នៅ

តំបន់ដាច់ស្រយាល ជាដើម ។ ចំពោះសន្តិសុខ និង ឯកជនភាពទិន្នន័យ, ទិន្នន័យមួយចំនួនដែលអ្នកប្រើ-ប្រាស់គិតថាមិនជាប់ពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ ដូចជា ប្រវត្តិនៃការស្វែងរកព័ត៌មានលើបណ្ដាញអ៊ីនធឺណិត, អាកប្បកិរិយាក្នុងការប្រើប្រាស់បណ្ដាញសង្គម និង ព័ត៌មានទាក់ទងនឹងផ្លូវចិត្ត ត្រូវបានយកទៅប្រើប្រាស់ ឬ រកចំណូលដោយមិនមានការអនុញ្ញាតពីអ្នកប្រើប្រាស់ ។

ទន្ទឹមនឹងដំណើរការទាញយកអត្ថប្រយោជន៍ និង ការកាត់បន្ថយហានិភ័យនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ, ប្រទេសក្នុងតំបន់ និង សកលលោក បាន និង កំពុងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ទៅតាមម៉ូដែលដែលអាចមានលក្ខណៈខុសៗគ្នា ។ ដើម្បីជាម៉ូដែលរួមដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, នៅឆ្នាំ ២០២០, Ehrentraud et al. បានបង្កើតម៉ូដែលដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលអាចជាកម្មវត្ថុនៃការចាប់យក, ការកែសម្រួល និង ការជំរុញនវានុវត្តន៍បន្ថែមតាមការចាំបាច់ ។ ដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាវត្តិកសាស្ត្របរិស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុ (Taxomony of the FinTech Environment) ដែលមានសមាសភាគផ្សំចំនួន ៣ គឺ (១)-បរិស្ថានគោលនយោបាយអំណោយផល (Policy Enablers), (២)-បច្ចេកវិទ្យាគាំទ្រ (Enabling Technologies) និង (៣)-សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Activities) ។

## ២.៣. ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌគោលនយោបាយ, យុទ្ធសាស្ត្រ និង ផែនទីបង្ហាញផ្លូវ ដែលរួមមានជាអាទិ៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ផែនទីបង្ហាញផ្លូវអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥ ដើម្បីលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

ទន្ទឹមនេះ, នៅឆ្នាំ ១៩៩៦, ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័ត ដើម្បីផ្តល់សិទ្ធិអំណាចដល់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំ និង ការគ្រប់គ្រងវិស័យធនាគារដែលរួមបញ្ចូលទាំងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ។ នៅឆ្នាំ ២០២១, អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានបង្កើតឡើងដោយធ្វើសមាហរណកម្មយន្តការនៃការគ្រប់គ្រង និង ការត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងគោលបំណងពង្រឹង និង ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង, ការត្រួតពិនិត្យ និង ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលមាននិយ័តករក្រោមឱវាទចំនួន ៦ និង មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាសេនាធិការ ។ នៅឆ្នាំ ២០២១, ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ត្រូវបានបង្កើតឡើងដើម្បីដឹកនាំសម្របសម្រួល និង ជំរុញការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជារស់រវើក ដែលមានគណៈកម្មាធិការចំនួន ៣ ជាសេនាធិការ គឺ គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល, គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និង គណៈកម្មាធិការសន្តិសុខឌីជីថល ។

លើសពីនេះ, ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង

ការជំរុញបរិវត្តកម្មឌីជីថល, ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន ត្រូវបានរៀបចំ ។ ក្នុងនោះ, ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តក្នុងវិស័យធនាគារ រួមមានជាអាទិ៍ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ ១៩៩៦ ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៦, ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ឆ្នាំ ១៩៩៧, ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩, ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និង ប្រតិបត្តិការទូទាត់សងប្រាក់ ឆ្នាំ ២០០៥, ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ឆ្នាំ ២០០៩, ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ឆ្នាំ ២០២០ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។ រីឯ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមានជាអាទិ៍ច្បាប់ស្តីពីការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជន ឆ្នាំ ២០០៧, ច្បាប់ស្តីពីការធានារ៉ាប់រងឆ្នាំ ២០១៤, ច្បាប់ស្តីពីគណនេយ្យ និង សវនកម្ម ឆ្នាំ ២០១៦, ច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ ២០១៩, ច្បាប់ស្តីពីបរធនបាលកិច្ច ឆ្នាំ ២០១៩, ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ ២០២១ និង លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ពាក់ព័ន្ធផ្សេងទៀត ។ ក្រៅពីនេះ, ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវបានរៀបចំដើម្បីជំរុញបរិវត្តកម្មឌីជីថល តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល, ភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល, ពលរដ្ឋឌីជីថល, រដ្ឋាភិបាលឌីជីថល និង ធុរកិច្ចឌីជីថល ។ បច្ចុប្បន្ន, រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗ ដែលមានបច្ច័យលើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមមានជាអាទិ៍ សេចក្តីព្រាងច្បាប់ស្តីពីអាជីវកម្ម និង សេវាអចលនវត្ថុ, សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអាជីវកម្មបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន, សេចក្តី-ព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ, សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និង សេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យបុគ្គល ។

លើសពីនេះ, ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ថ្នាលឌីជីថលគ្រឹះ ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ, រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការប្រព័ន្ធបាគង និង ស្តង់ដាខេអេចឃ្យូអរ, សេវាទូទាត់រហ័ស (FAST Payment), ប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System – NCS), ប្រព័ន្ធខេមបូឌានស៊ែស្វិច (Cambodian Shared Switch – CSS), ប្រព័ន្ធរីធែលផេ (Retail Pay) និង ប្រព័ន្ធធនាគារអនឡាញ (Online Banking System – OBS), ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX), ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (CamDigiKey), ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh និង ថ្នាលបច្ចេកវិទ្យាប្លុកឆេនកម្ពុជា (Cambodia Distributed Ledger – CamDL) សម្រាប់សាកល្បងកម្មវិធីវេប ៣ (Web 3) ដើម្បីជំរុញការប្រើប្រាស់ និង នវានុវត្តន៍បច្ចេកវិទ្យាដែលកំពុងលេចឡើងថ្មីៗ ។ បន្ថែមលើនេះ, ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ, រាជរដ្ឋាភិបាលបានគាំទ្រដល់ការរៀបចំជាអាទិ៍ កម្មវិធីពន្លឿនអាជីវកម្មនវានុវត្តន៍បញ្ញាស, វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, មហោស្រពបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោក, វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុនៃពិព័រណ៍បច្ចេកវិទ្យាកម្ពុជា និង យុទ្ធនាការ "តោះ! និយាយពីលុយ" ជាដើម ។

ជាមួយនឹងការគាំទ្រពីរាជរដ្ឋាភិបាលប្រកបដោយចក្ខុវិស័យវែងឆ្ងាយ, បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា មានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍទៅថ្ងៃអនាគត ។ ចំនួនដ៏ច្រើននៃប្រជាជនវ័យក្មេង, ការកើនឡើងនៃវិសាលភាពគ្របដណ្តប់នៃបណ្តាញអ៊ីនធឺណិតល្បឿនលឿន ព្រមទាំងការកើនឡើងនៃការប្រើប្រាស់បណ្តាញសង្គម និង ថ្នាលឌីជីថលនានា នឹងធ្វើឱ្យសម្ទុះនៃការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាទូទៅ ក៏ដូចជាបច្ចេកវិទ្យាហិរញ្ញវត្ថុមានការកើនឡើង ។ បន្ថែមលើនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ មាននវានុវត្តន៍ខ្លាំង ខណៈនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារក៏កំពុងរីកលូតលាស់គួរឱ្យកត់សម្គាល់ផងដែរ ។ ការកើនឡើងនៃការប្រើប្រាស់ការទូទាត់សងប្រាក់ឌីជីថលក្នុងវិស័យសាធារណៈ និង វិស័យឯកជន, និង ពីសំណាក់ប្រជាពលរដ្ឋ មានការកើនឡើងល្អគួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង, គិតត្រឹមឆ្នាំ ២០២២, ក្នុងវិស័យធនាគារ ចំនួនប្រតិបត្តិការសេវាទូទាត់សងប្រាក់បានកើនដល់ប្រមាណ ១ ប៊ីលានប្រតិបត្តិការ ក្នុងទំហំទឹកប្រាក់ ២៧២,៥ ប៊ីលានដុល្លារអាម៉េរិក, គណនីកាបូបលុយអេឡិចត្រូនិកមានចំនួន ១៧,៩ លានគណនី, គណនីឥណទានមានចំនួន ៣,៧ លានគណនី និង គណនីប្រាក់បញ្ញើមានចំនួន ១៤,៣ លានគណនី ។

ក្រៅពីវិស័យធនាគារ, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរ ជាពិសេសក្នុងអំឡុង និង ក្រោយវិបត្តិសកលនៃជំងឺកូវីដ-១៩ បន្ទាប់ពីមានការគាំទ្រខ្ពស់ពីរាជរដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មយន្តការស្ថាប័ន និង ការអភិវឌ្ឍវិស័យនេះកន្លងមក ។ ជាការកត់សម្គាល់, វិស័យហិរញ្ញវត្ថុមិនមែនធនាគារកម្ពុជា បាន និង កំពុងចូលរួមចំណែកយ៉ាងសំខាន់ដល់ការជំរុញសម្ទុះកំណើនសេដ្ឋកិច្ចជាតិ ។ តួយ៉ាង គិតត្រឹមឆ្នាំ ២០២១, វិស័យធានារ៉ាប់រងបានចូលរួមចំណែក ១,១១% នៃផលិតផលក្នុងស្រុកសរុប ជាមួយនឹងដង់ស៊ីតេធានារ៉ាប់រង ១៨,៦១ ដុល្លារអាម៉េរិកក្នុងមនុស្សម្នាក់ ដែលក្នុងនោះក៏មានការរួមចំណែកពីបច្ចេកវិទ្យាធានារ៉ាប់រងផងដែរ ។ បន្ថែមលើនេះ, វិស័យធានារ៉ាប់រងមានបុព្វលាភសរុប ៣០០ លានដុល្លារអាម៉េរិក និង ទ្រព្យសកម្មសរុប ៨៥០ លានដុល្លារអាម៉េរិក ។ សម្រាប់វិស័យមូលបត្រ, មូលធនូបនីយកម្មទីផ្សារសម្រាប់ទីផ្សារមូលបត្រមានចំនួនសរុប ១,៨៧ ប៊ីលានដុល្លារអាម៉េរិក, ការប្រមូលសាច់ប្រាក់ពីទីផ្សារមូលបត្រមានចំនួនសរុប ៣១៧,៥៥ លានដុល្លាអាម៉េរិក និង ទំហំជួញដូរនៃទីផ្សារឧបករណ៍និស្សន្ទមានចំនួនសរុប ៣០០,៥១ លានដុល្លារអាម៉េរិក នៅឆ្នាំ ២០២២ ។ សមិទ្ធផលទាំងនេះ ជាការរួមចំណែកនៃបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ តាមរយៈការដាក់ឱ្យប្រើប្រាស់នូវ (១)-ប្រព័ន្ធជួញដូរចល័ត និង កម្មវិធីទូរសព្ទ ស៊ីអេសអ៊ិកត្រេដ (CSX Trade), (២)-ប្រព័ន្ធផ្តល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ, (៣)-ប្រព័ន្ធ និង កម្មវិធីទូរសព្ទជួញដូរឧបករណ៍និស្សន្ទ, (៤)-ប្រព័ន្ធបើកគណនីជួញដូរមូលបត្រ និង (៥)- គណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ។ បច្ចុប្បន្ន, និយ័តករ និង អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បាន និង កំពុងខិតខំជំរុញបរិវត្តកម្មឌីជីថលក្នុងសមត្ថកិច្ចរបស់ខ្លួន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាត្រួតពិនិត្យ (Supervisory Technology – SupTech) និង បច្ចេកវិទ្យានិយ័តកម្ម (Regulatory Technology – RegTech) ។ ក្នុង

ស្នារតីជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ, បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ និង វិស័យធានារ៉ាប់រង ត្រូវបានដាក់ឱ្យដំណើរការ ។

ទោះបីជាយ៉ាងនេះក្តី, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួន រួមមាន (១)-កង្វះបរិស្ថានគោលនយោបាយអំណោយផល, កង្វះ និង ភាពមិនច្បាស់លាស់នៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាកង្វះសមាមាត្រភាពក្នុងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត, (២)-កង្វះថ្នាលឌីជីថលគ្រឹះ, (៣)-កង្វះការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រ និង (៤)-កង្វះការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ក្នុងនោះ, កម្ពុជាអាចទទួលរងនូវហានិភ័យបច្ចេកវិទ្យាហិរញ្ញវត្ថុជាពិសេសហានិភ័យដែលអាចកើតមានពីកង្វះបរិយាបន្នហិរញ្ញវត្ថុ ។ កង្វះបរិយាបន្នហិរញ្ញវត្ថុ អាចកើតឡើងតាមរយៈភាពមានកម្រិតនៃអក្ខរកម្មឌីជីថល និង អក្ខរកម្មហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ក្នុងប្រទេស ។ ស្របពេលដែលអក្ខរកម្មឌីជីថល និង អក្ខរកម្មហិរញ្ញវត្ថុរបស់ប្រជាជននៅមានកម្រិត, ហានិភ័យលើសន្តិសុខ និង ឯកជនភាពទិន្នន័យ ក៏អាចកើតមានឡើង តាមរយៈការលួច ឬ ការប្រើប្រាស់ទិន្នន័យដោយពុំស្របច្បាប់ ដែលនឹងបង្កើតឱ្យមានការរំលោភបំពានលើឯកជនភាពទិន្នន័យរបស់អ្នកប្រើប្រាស់ ។

ជារួម, ផ្អែកលើមូលដ្ឋានទិន្នន័យ និង ការវាយតម្លៃខាងលើ, ទោះបីស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ពិតមែន, បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាស្ថិតនៅដំណាក់កាលលូតលាស់ដំបូង និង មិនទាន់មានតុល្យភាពរវាងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលការណ៍នេះតម្រូវឱ្យមានការគិតគូរជាប្រព័ន្ធ និង គ្រប់ជ្រុងជ្រោយបន្ថែមទៀត ។ ក្នុងន័យនេះ, ប្រសិនបើប្រៀបធៀបនឹងដើមឈើមួយដើម, ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាប្រៀបដូចជាកូនដើមឈើមួយដើមដែលមិនទាន់លូតលាស់ល្អនៅឡើយ ដោយហេតុថា ដីមិនទាន់មានជីជាតិគ្រប់គ្រាន់ដែលអំណោយផលដល់ការស្រូបយករបស់ឫស។ ទន្ទឹមនេះ, ឫសនៅមានចំនួនតិចតួច និង មិនទាន់ចាក់ស្រេះជាមូលដ្ឋានគ្រឹះរឹងមាំ ។ រីឯ ដើមទៀតសោតនៅមានទំហំតូច, មិនទាន់រឹងមាំ និង មានភាពផុយស្រួយ ដែលអាចងាយបាក់ដោយការប៉ះទង្គិចផ្សេងៗ ។ ចំណែកឯ, ស្លឹក និង មែក, ថ្វីត្បិតមានការដុះលូតលាស់ចេញជារូបរាងមួយចំនួនក៏ពិតមែន, ការដុះលូតលាស់នេះហាក់ពុំស្មើគ្នា ដោយមានមែកម្ខាងធំ និង ម្ខាងតូច ដូចមានបង្ហាញក្នុងរូបភាពទី ១ ។ ប្រសិនបើប្រៀបធៀបនឹងប្រទេសក្នុងតំបន់, ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា មិនស្ថិតនៅក្រោយគេនោះទេ, ប៉ុន្តែស្ថិតនៅក្នុងចំណោមប្រទេសដែលចាត់ទុកថា មិនទាន់អាចទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាហិរញ្ញវត្ថុនៅឡើយ ។ ជាការគិតគូរទៅមុខ, គោលនយោបាយនេះ នឹងធ្វើឱ្យស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាលូតលាស់ទៅជាដើមឈើធំមួយដើម ដែលអាចអាស្រ័យផលបាន និង ជាម្លប់ដ៏ត្រឈឹងត្រឈៃផងដែរ ។

## រូបភាពទី ១. ការប្រៀបធៀបការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៃប្រទេសក្នុងតំបន់អាស៊ាន



## ៣. ក្របខណ្ឌគោលនយោបាយ

គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ៥ ឆ្នាំ គឺចាប់ផ្ដើមពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០២៨ ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក៏ដូចជានៅក្នុងតំបន់ និង សកលលោក ។ គោលនយោបាយនេះ កំណត់អំពីទស្សនាទានរួម និង វិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដែលអនុលោមតាមឧត្តមានុវត្តន៍ និង និន្នាការអន្តរជាតិនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលមានសមានគតិភាពជាមួយនឹងបរិការណ៍កម្ពុជា ។

### ៣.១. ចក្ខុវិស័យ គោលបំណង និង គោលដៅ

ឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, រាជរដ្ឋាភិបាល ដាក់ចេញនូវចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា គឺ **"អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្ដល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក"** ។

បម្រើឱ្យចក្ខុវិស័យរយៈពេលវែងខាងលើនេះ, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ មានគោលបំណង **"អភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក តាមរយៈការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ, ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល"** ។

ដើម្បីសម្រេចចក្ខុវិស័យ និង គោលបំណងខាងលើ, គោលនយោបាយនេះ កំណត់យកគោលដៅចម្បងដែលជាផ្នែកទាំង ៤ នៃដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុ ដូចក្នុងរូបភាពទី ២ ខាងក្រោម៖

## រូបភាពទី ២. ដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា




*ប្រភព៖ កែសម្រួលពី Ehrentraud et al. (2020)*

១)- **ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល ដែលតំណាងដោយ "ដី"៖** ផ្តោតលើការអភិវឌ្ឍបរិស្ថានដែលមានលក្ខណៈអំណោយផលជាអាទិ៍ការរៀបចំក្របខណ្ឌគោល-នយោបាយ, ការរៀបចំ និង ការធ្វើវិសោធនកម្មក្របខណ្ឌគតិយុត្ត ឬ និយ័តកម្ម, ការរៀបចំក្របខណ្ឌអន្តរប្រតិបត្តិការ, ការលើកកម្ពស់ភាពជឿទុកចិត្ត, ការពង្រឹងកិច្ចសហការ និង កិច្ច-សហប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធ និង ការផ្តួចផ្តើមគំនិតនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងទៀត ។ ដូចគ្នាទៅនឹងដីមានជីជាតិដែលមានលក្ខណៈអំណោយផលដល់ការស្រូបយកជីជាតិរបស់ឫស និង ជាមូលដ្ឋានទ្រទ្រង់ដល់ដើមឈើទាំងមូល, ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល គាំទ្រដល់ការអភិវឌ្ឍឋ្នាលឌីជីថលគ្រឹះ, ការលើកកម្ពស់ការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ព្រមទាំងការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

២)- **ការអភិវឌ្ឍថ្នាលឱដីជីថលគ្រឹះ ដែលតំណាងដោយ "ឫស"៖** ផ្តោតលើការជំរុញការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់ និង ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះចាំបាច់ដទៃទៀត សម្រាប់គាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនិយាយដោយឡែក និង ការអភិវឌ្ឍឌីជីថលនិយាយជារួម ។ ថ្នាលឌីជីថលគ្រឹះប្រៀបបាននឹងឫសច្រើន និង មាំ ដែលអាចស្រូបយកជីជាតិពីក្នុងដីបានល្អ សម្រាប់ទ្រទ្រង់ភាពរឹងមាំរបស់ដើម និង ការបែកសាខារបស់មែក ។ ទោះបីជាដីមានជីជាតិយ៉ាងណាក៏ដោយ, ប្រសិនបើឫសមិនមានច្រើន និង មិនមាំដែលអាចស្រូបយកជីជាតិពីក្នុងដីទៅដើមឈើបាន, ដើមឈើក៏នឹងមិនអាចដុះលូតលាស់ និង ផ្តល់ផ្លែផ្កាសម្រាប់អាស្រ័យផលរបស់សត្វទាំងពួងបានទេ ។ ដូច្នេះ, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ពិតជាមានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

៣)- **ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដែលតំណាងដោយ "ដើម"៖** ផ្តោតលើជាអាទិ៍ការស្រាវជ្រាវ និង ការអភិវឌ្ឍ, ការលើកកម្ពស់អក្ខរកម្ម, ការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យា ដើម្បីជំរុញការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យសាធារណៈ និង វិស័យឯកជន។ ដូចគ្នាទៅនឹងដើមដែលមានភាពរឹងមាំសម្រាប់ទ្រទ្រង់ដល់ការលូតលាស់ល្អ និង ការបែកសាខារបស់មែក, ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យា មានភាពចាំបាច់ក្នុងការគាំទ្រដល់ការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

៤)- **ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលតំណាងដោយ "មែក"៖** ផ្តោតលើការជំរុញពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រកបដោយនវានុវត្តន៍ ក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារឱ្យមានភាពសម្បូរបែប ដែលអាចដើរស្របនឹងនិន្នាការតំបន់ និង សកល ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ។ ដូចគ្នាទៅនឹងមែកដែលបែកសាខាប្រកបដោយផ្លែផ្កាច្រើន ដែលអាចអាស្រ័យផលបាន, ភាពសម្បូរបែបនៃសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារ ធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ, ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នកប្រើប្រាស់ ។

ក្រៅពីចំណុចគោលដែលបានបកស្រាយខាងលើ, ចំណុចដែលពាក់ព័ន្ធនឹងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងទៀតមានដូចជា "សរសៃឈាម" តូចៗ នៅក្នុងដើម ដែលតំណាងឱ្យលំហូរនៃទិន្នន័យ, ចំណេះដឹង និង មូលធន និង ជាផ្នែកមួយមិនអាចខ្វះបានសម្រាប់ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុ ។ "សត្វកំប្រុក" តំណាងឱ្យធុរកិច្ចបច្ចេកវិទ្យាហិរញ្ញវត្ថុ រីឯ "សត្វចាប" តំណាងឱ្យអ្នកប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ជាមួយគ្នានេះដែរ, "អាកាសធាតុ" ដែលមានឥទ្ធិពលដល់ការរីកលូតលាស់របស់ដើមឈើដូចជា ទីផ្សារមូលធន, សន្ទនីយភាព, កិច្ចសហប្រតិបត្តិការ, ការគ្រប់គ្រងហានិភ័យ និង មូលធនមនុស្ស សុទ្ធតែអាចមានឥទ្ធិពលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

## ៣.២. គោលការណ៍ និង អភិក្រម

សម្រាប់ការអនុវត្តគោលនយោបាយនេះ, រាជរដ្ឋាភិបាលកំណត់យកគោលការណ៍ធំៗ ចំនួន ៣ គឺ (១)-ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, (២)-ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង (៣)-ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដូចមានបង្ហាញក្នុងរូបភាពទី ៣ ខាងក្រោម។

ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាដោយផ្អែកលើគោលការណ៍ខាងលើ, ការអនុវត្តគោលនយោបាយនេះ ប្រើប្រាស់អភិក្រមចម្បងចំនួន ៣ ដូចខាងក្រោម ៖

១)- **ការចាប់យក** (Adoption)៖ សំដៅដល់ការចាប់យកចំណេះដឹង,បទពិសោធ និង ឧត្តមានុវត្តន៍អន្តរជាតិនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា,

២)- **ការសម្រប** (Adaptation)៖ សំដៅដល់ការកែសម្របចំណេះដឹង, បទពិសោធ និង ឧត្តមានុវត្តន៍អន្តរជាតិនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកម្ពុជាបានចាប់យក ដោយធ្វើយ៉ាងណាឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា និង

៣)- **ការធ្វើនវានុវត្តន៍បន្ថែម** (Further Innovation)៖ សំដៅដល់ការធ្វើនវានុវត្តន៍បន្ថែមទៅលើចំណេះដឹង, បទពិសោធ និង ឧត្តមានុវត្តន៍អន្តរជាតិនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកម្ពុជាបានចាប់យក និង កែសម្រប ប្រកបដោយគំនិតច្នៃប្រតិដ្ឋ ដើម្បីបង្កើតកាលានុវត្តភាពថ្មីៗក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ។

**រូបភាពទី ៣. គោលការណ៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា**



## ៣.៣. វិធានការគោលនយោបាយ

វិធានការគោលនយោបាយ ត្រូវបានរៀបចំស្របតាមគោលដៅចម្បងចំនួន ៤ ខាងលើគឺ (១)-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, (២)-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, (៣)-ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង (៤)-ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

### ៣.៣.១. ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល

ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល សំដៅដល់ការរៀបចំ និង ការធ្វើសុខុដុមនីយកម្មវិធានការ និង ការផ្តួចផ្តើមគំនិត ដែលបង្កលក្ខណៈអំណោយផលដល់ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រ ព្រមទាំងការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ក្នុងការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, រាជរដ្ឋាភិបាលបានកំណត់នូវវិធានការគោល-នយោបាយខាងក្រោម៖

១)- ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យ និង ការចែករំលែកទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ,

២)- សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំ និង ការដាក់ឱ្យប្រើប្រាស់ ឬ ការអនុវត្តក្របខណ្ឌគាំទ្រអភិបាលកិច្ចសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interfaces–APIs) និង អន្តរប្រតិបត្តិការ ព្រមទាំងអន្តរតំណភាពរវាងតួអង្គពាក់ព័ន្ធក្នុងឧស្សាហកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសរវាងនិយ័តករ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ,

៣)- ប្រយុទ្ធនឹងបទល្មើសហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម និង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ,

៤)- ពិនិត្យលទ្ធភាពក្នុងការដាក់ចេញក្របខណ្ឌធនាគារបើកចំហ (Open Banking Framework),

៥)- ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និង/ឬ ពហុភាគីជាមួយនឹងប្រទេសក្នុងតំបន់ ដើម្បីគាំទ្រការទូទាត់សងប្រាក់ ឬ ការផ្ទេរប្រាក់ឆ្លងដែន,

៦)- កែសម្រួល ឬ ធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួនក្នុងវិស័យហិរញ្ញវត្ថុដែលអាចរាំងស្ទះ ឬ បង្កើតភាពស្មុគស្មាញដល់ការអភិវឌ្ឍ និង នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ,

៧)- រៀបចំ, កែសម្រួល ឬ ធ្វើវិសោធនកម្មបទប្បញ្ញត្តិប្រុងប្រយ័ត្ន (Prudential Regulations) ដែលអនុវត្តចំពោះបច្ចេកវិទ្យាហិរញ្ញវត្ថុតាមការចាំបាច់ និង ចូលរួមលើកកម្ពស់ការការពារសន្តិសុខបច្ចេកវិទ្យាព័ត៌មានក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ,

៨)- រៀបចំក្របខណ្ឌ ឬ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការវាយតម្លៃ និង ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Risk Assessment and Management),

៩)- គាំទ្រ និង ជំរុញការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ ជាពិសេសសន្តិសុខឌីជីថល ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីគតិយុត្ត ឬ ប្រព័ន្ធអេកូឡូស៊ីនិយ័តកម្ម សំដៅលើកកម្ពស់ភាពជឿទុកចិត្តលើបច្ចេកវិទ្យាហិរញ្ញវត្ថុ,

១០)-សិក្សា និង រៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ រួមទាំងកិច្ចការពារទិន្នន័យ និងឯកជនភាព,

១១)-សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំ, ការដាក់ឱ្យដំណើរការ និង ការអភិវឌ្ឍបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងតាមដានជាប្រចាំនូវប្រតិបត្តិការរបស់បុគ្គលចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុជាមួយនឹងនិយ័តករបរទេស,

១២)-រៀបចំផែនការមេកសាងសមត្ថភាព និង ជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុដល់គ្រប់តួអង្គពាក់ព័ន្ធ ជាពិសេសសមត្ថភាពស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ,

១៣)-កសាងបណ្តាញទំនាក់ទំនងជាមួយនឹងវិស័យឯកជន ដែលធ្វើកិច្ចប្រតិបត្តិការបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការចូលរួមពីវិស័យឯកជនក្នុងភាពជាដៃគូល្អនៃការកសាង និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាព,

១៤)-កសាងបណ្តាញទំនាក់ទំនងជាមួយនឹងនិយ័តករហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនអន្តរជាតិនានា ដែលធ្វើប្រតិបត្តិការបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីសិក្សា, ស្វែងយល់ និង ជំរុញឱ្យមានការផ្លាស់ប្តូរមតិយោបល់ ក៏ដូចជាការចែករំលែកចំណេះដឹង, បទពិសោធ និង ឧត្តមានុវត្តន៍,

១៥)-រៀបចំ, កែសម្រួល និង ជំរុញការអនុវត្តផែនការអភិវឌ្ឍស្ថាប័នរបស់និយ័តករ និង អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយរំលេចឱ្យឃើញពីការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ,

១៦)-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បន្ទាប់ពីគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល,

១៧)-សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយធ្វើសុខដុមនីយកម្មមុខងារបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការបែងចែកមុខងាររវាងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឱ្យបានច្បាស់លាស់ និង មិនធ្វើឱ្យមានបម្រែបម្រួលជារចនាសម្ព័ន្ធដល់ស្ថាប័នដែលមានស្រាប់, ការកំណត់ប្រភេទបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ និង ធានានិយ័តភាពសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារក្នុងទីផ្សារ ព្រមទាំងកំណត់អំពីគោលការណ៍និយ័តកម្ម និង ត្រួតពិនិត្យសំខាន់ៗពាក់ព័ន្ធផ្សេងទៀត,

១៨)-រៀបចំយន្តការសហការ, សម្របសម្រួល និង ធ្វើកិច្ចសហប្រតិបត្តិការផ្ទៃក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារជាមួយនឹងធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនសហថាមពល, សហនវានុវត្តន៍, សហការទទួលខុសត្រូវ, សិនិទ្ធភាព និង សុខដុមនីយកម្មមុខងារនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ, និង

១៩)-រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ និង ការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល និង បទប្បញ្ញត្តិគ្រប់គ្រងប្រតិបត្តិការហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល ។

### ៣.៣.២. ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ

ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ សំដៅដល់ការជំរុញការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់ និង ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះថ្មីៗ ព្រមទាំងបច្ចេកវិទ្យានិយ័តកម្ម និង បច្ចេកវិទ្យាត្រួតពិនិត្យ ដោយលើកកម្ពស់ការចែករំលែក និង ការបើកចំហទិន្នន័យ និង បរិវត្តកម្មឌីជីថលក្នុងស្ថាប័ន ។ ក្នុងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, រាជរដ្ឋាភិបាលបានកំណត់នូវវិធានការគោលនយោបាយដូចខាងក្រោម៖

១)- អភិវឌ្ឍ និង ដាក់ឱ្យប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលសម្រាប់វិស័យហិរញ្ញវត្ថុ,

២)- ជំរុញការស្រាវជ្រាវ, ការសាកល្បង និង ការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់ ព្រមទាំងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះផ្សេងទៀតសម្រាប់ហិរញ្ញវត្ថុវិមជ្ឈការ,

៣)- អភិវឌ្ឍ និង ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ដើម្បីគាំទ្រសេវា និង លើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់សងប្រាក់ឌីជីថល,

៤)- រៀបចំក្របខណ្ឌនិយ័តកម្ម និង ការត្រួតពិនិត្យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលរួមបញ្ចូលនូវការប្រើ-ប្រាស់បច្ចេកវិទ្យានិយ័តកម្ម ដើម្បីជួយ និង ពង្រឹងអនុលោមភាពនិយ័តកម្មឱ្យកាន់តែមានប្រសិទ្ធភាពជាងសមត្ថភាពដែលមានស្រាប់ និង បច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីជួយដល់ការធ្វើឌីជីតូបនីយកម្មការរាយការណ៍ និង ដំណើរការនិយ័តកម្ម (Digitization of Reporting and Regulatory Processes) ដែលសំដៅគាំទ្រដំណើរការនៃការត្រួតពិនិត្យហានិភ័យ និង អនុលោមភាព ប្រកបដោយភាពបុរេសកម្ម និង ប្រសិទ្ធភាព,

៥)- សិក្សាសមិទ្ធិលទ្ធភាពក្នុងការចែករំលែក និង ការបើកចំហទិន្នន័យ ដើម្បីផ្តល់កាលានុវត្តភាពថ្មីៗ ដល់ការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ,

៦)- ជំរុញការប្រើប្រាស់ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលដែលមានស្រាប់ ដូចជា ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា សម្រាប់ធ្វើយថាភូតកម្ម, ផ្ទៀងផ្ទាត់ និង ប្រើប្រាស់ទិន្នន័យអត្តសញ្ញាណសម្គាល់អតិថិជនឌីជីថល ដើម្បីលើកកម្ពស់គុណភាព, ភាពជឿទុកចិត្ត, ប្រសិទ្ធភាព និង សក្តិសិទ្ធិភាពនៃការផ្តល់, ការទទួលបាន និង ការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល,

៧)- ជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថល (Digital Signature) ដើម្បីលើកកម្ពស់សុវត្ថិភាព និង ប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ,

៨)- ជំរុញការប្រើប្រាស់ថ្នាល verify.gov.kh ដើម្បីផ្ទៀងផ្ទាត់ និង បញ្ជាក់ភាពត្រឹមត្រូវនៃឯកសារឌីជីថលដែលបានចេញដោយក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល,

៩)- ពង្រឹង និង ពង្រីកការប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុឌីជីថល ឱ្យក្លាយទៅជាប្រព័ន្ធមួយដែលមានចរិតលក្ខណៈអន្តរក្រសួង-ស្ថាប័ន ឈរលើគោលការណ៍ "**ធ្វើតែមួយលើកគត់**" (The Once-only Principle),

១០)-រៀបចំកម្មវិធីលើកកម្ពស់ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ដែលគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការចាប់យក, ការប្រើប្រាស់, ការកែសម្រួល, នវានុវត្តន៍ និង ការធ្វើពិពិធកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ,

១១)-ជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការរៀបចំ និង ការធ្វើទំនើបកម្មស្ថាប័ន ដូចជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាល, ប្រព័ន្ធចុះបញ្ជី, ប្រព័ន្ធ ឬ ថ្នាលប្រមូល និង គ្រប់គ្រងទិន្នន័យ, ប្រព័ន្ធវិភាគ និង ផ្តល់សញ្ញាមុន, ថ្នាលផ្តល់សេវាសាធារណៈ និង ថ្នាលផ្សេងៗទៀត, និង

១២)-ស្រាវជ្រាវអំពីហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ (Data Infrastructures) គាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ។

### ៣.៣.៣. ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ

ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ សំដៅដល់ការជំរុញឱ្យវិស័យសាធារណៈ និង វិស័យឯកជនចាប់យក ប្រើប្រាស់ និង អភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដោយលើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ, ពង្រឹងកិច្ចសហការ និង កិច្ចសហប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធ, លើកកម្ពស់អក្ខរកម្ម និង ការបណ្តុះបណ្តាលជំនាញ ពាក់ព័ន្ធនឹងបច្ចេកវិទ្យា ដែលគាំទ្រការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេក-វិទ្យាហិរញ្ញវត្ថុ ។ ក្នុងការលើកកម្ពស់ការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, រាជរដ្ឋាភិបាលបានកំណត់នូវវិធានការគោលនយោបាយ ដូចខាងក្រោម៖

១)- រៀបចំវេទិកាសាធារណៈ, ព្រឹត្តិការណ៍, កម្មវិធីប្រកួតប្រជែង, កម្មវិធីពិព័រណ៍ ឬ យុទ្ធនាការផ្សេងៗ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍ ក៏ដូចជាកាលានុវត្តភាពនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយសហការ, សម្របសម្រួល និង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងតួអង្គពាក់ព័ន្ធតាមការចាំបាច់,

២)- សហការជាមួយនឹងគ្រប់តួអង្គសង្គមពាក់ព័ន្ធ ដើម្បីដាក់ចេញកម្មវិធីស្តីពីអក្ខរកម្មហិរញ្ញវត្ថុ, អក្ខរកម្មឌីជីថល និង ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដល់សាធារណជនទូទៅ និង សហគ្រិន,

៣)- រៀបចំផតថលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Portal) ដើម្បីចែកចាយ និង ចែករំលែកទិន្នន័យ, ព័ត៌មាន, ឯកសារ និង ចំណេះដឹងផ្សេងៗ សំដៅគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាព,

៤)- ជំរុញការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រគន្លឹះៗ ដូចជា បញ្ញាសិប្បនិម្មិត (Artificial Intelligence – AI), ម៉ាស៊ីនស្វ័យសិក្សា (Machine Learning – ML), ទិន្នន័យធំ, បច្ចេកវិទ្យាក្លោដ (Cloud Computing), បច្ចេកវិទ្យាប្លុកឆេន (Blockchain Technology), កិច្ចសន្យាឆ្លាត (Smart Contract), បច្ចេកវិទ្យាប្រព្រឹត្តិកម្មភាសាធម្មជាតិ (Natural Language Processing – NLP), បច្ចេកវិទ្យាតថភាពនិម្មិត (Virtual Reality Technology) និង បច្ចេកវិទ្យាវិភាគទិន្នន័យ ដើម្បីជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ,

៥)- ជំរុញ និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាដល់ធុរជន, សហគ្រិន និង សាធារណជន ដើម្បីផ្លាស់ប្តូរឥរិយាបថ និង លើកកម្ពស់ភាពជឿទុកចិត្តលើបច្ចេកវិទ្យាហិរញ្ញវត្ថុ,

៦)- ជំរុញ និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាដល់ថ្នាក់ដឹកនាំ និង មន្ត្រី ដើម្បីកសាង និង អភិវឌ្ឍភាពជាអ្នកដឹកនាំ និង សមត្ថភាពពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ,

៧)- រៀបចំថ្នាលលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីបង្កើត, រក្សាទុក, ផ្ទេរ ឬ ចែករំលែកចំណេះដឹងបច្ចេកវិទ្យាឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុ,

៨)- ជំរុញឱ្យមានការរៀបចំកម្មវិធីបណ្តុះបណ្តាល និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសិក្សា, អប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ,

៩)- រៀបចំ និង ធ្វើបច្ចុប្បន្នកម្មសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Lexicon) ដើម្បីលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ,

១០)-លើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ និង នវានុវត្តន៍បច្ចេកវិទ្យា ដែលគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមបញ្ចូលចាប់ពីកម្រិតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ,

១១)-អភិវឌ្ឍ និង អនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ១ ២ ៣ ៤ លើជំនាញឌីជីថលសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេស, និង

១២)-សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំឱ្យមានប្រព័ន្ធគាំពារសុខុមាលភាពអតិថិជន តួយ៉ាង ការថែទាំ និង ការគាំទ្រអតិថិជន និង ការដោះស្រាយបណ្តឹង ដោយប្រើប្រាស់បច្ចេកវិទ្យា ។

### ៣.៣.៤. ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ

ការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅដល់ការធ្វើពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលរួមបញ្ចូលទាំងហិរញ្ញវត្ថុ

វិមជ្ឈការ ( DeFi ) ឬ បច្ចេកវិទ្យាដែលកំពុងលេចឡើង ( Emerging Tech ) ។ ក្នុងការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, រាជរដ្ឋាភិបាលបានកំណត់នូវវិធានការគោលនយោបាយ ដូចខាងក្រោម៖

១ )- ដាក់ចេញបទប្បញ្ញត្តិ និង គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការផ្តល់ប្រាក់កម្ចីឌីជីថល ប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព,

២ )- ពង្រឹងក្របខណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន និង យន្តការសុវត្ថិភាពក្នុងប្រតិបត្តិការទូទាត់សងប្រាក់ ឌីជីថល,

៣ )- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយទូទាត់សងប្រាក់ឌីជីថលជាមួយនឹងវិស័យសាធារណៈ និង វិស័យឯកជន,

៤ )- លើកកម្ពស់ផលិតផល និង សេវាធនាគារឌីជីថលប្រកបដោយនវានុវត្តន៍,

៥ )- ជំរុញគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុឱ្យដាក់ប្រើប្រាស់នូវការផ្តល់ប្រាក់កម្ចី ឬ សន្សំប្រាក់ឌីជីថល,

៦ )- ជំរុញការអភិវឌ្ឍ និង ការប្រើប្រាស់ផលិតផល និង សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុ និង កម្មវិធីវិមជ្ឈការ ( Decentralized Application – dApp ) ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន,

៧ )- ជំរុញឱ្យមានការលើកទឹកចិត្តសារពើពន្ធ, ការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ការគាំទ្រផ្សេងទៀតដល់ សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ,

៨ )- លើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ ដើម្បីបង្កើននវានុវត្តន៍សេវា និង ផលិតផល និង ធ្វើ ពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ, និង

៩ )- លើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការរៀបចំ វេទិកា, សិក្ខាសាលា និង កម្មវិធីផ្សេងៗ រួមទាំងកម្មវិធីបណ្តុះ និង ពន្លឿនធុរកិច្ចថ្មីបច្ចេកវិទ្យា ហិរញ្ញវត្ថុ ។

## ៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ

ការរៀបចំយន្តការអនុវត្តគោលនយោបាយ ផ្អែកលើយន្តការស្ថាប័នដែលមានស្រាប់ក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំង ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន ក្រោមការសម្របសម្រួល និង ការដឹកនាំដោយគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ។ ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ត្រូវរៀបចំផែនការសកម្មភាពការងារឱ្យបានច្បាស់លាស់ និង រៀបចំផែនការថវិកាសម្រាប់ចំណាយលើការអនុវត្តផែនការសកម្មភាព ដែលត្រូវប្រើយន្តការប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។ ទន្ទឹមនេះ, ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ចាំបាច់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវផែនការដែលបានដាក់ចេញ និង បង្ហាញនូវគណនេយ្យភាពនៃការប្រើប្រាស់ថវិកា ។

គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ទទួលបន្ទុករៀបចំយន្តការតាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយនេះ ដែលរួមមាន ការតាមដាន និង ការវាយតម្លៃ, ការអនុវត្តសកម្មភាព, សូចនាករលទ្ធផល និង សូចនាករបច្ច័យ ទៅតាមការិយបរិច្ឆេទសំខាន់ៗ យោងទៅតាមតារាងវិធានការគោលនយោបាយនៅក្នុងឧបសម្ព័ន្ធ ។ ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ត្រូវចូលរួមសហការជាមួយនឹងគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ក្នុងការផ្តល់ទិន្នន័យ និង របាយការណ៍ជាទៀងទាត់ ដើម្បីឱ្យគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល បូកសរុបជារបាយការណ៍ដាក់ជូនរាជរដ្ឋាភិបាល ។

ទោះបីជាភាពរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ បាន និង កំពុងផ្តល់បច្ច័យវិជ្ជមានជាច្រើនដល់សេដ្ឋកិច្ច និង សង្គម, បច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏អាចបង្កហានិភ័យផងដែរ ។ អាស្រ័យហេតុនេះ, ក្នុងស្មារតីបុរេសកម្ម, ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ ចាំបាច់ត្រូវសិក្សា និង រៀបចំក្របខណ្ឌវាយតម្លៃ និង គ្រប់គ្រងហានិភ័យដែលអាចបណ្តាលមកពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីត្រៀមលក្ខណៈកាត់បន្ថយហានិភ័យទាំងនោះឱ្យស្ថិតក្នុងកម្រិតអប្បបរមា ។

# ៩. សន្និដ្ឋាន

ឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, រាជរដ្ឋាភិបាលបានដាក់ចេញនូវ **"គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"** ស្របតាមឧត្តមានុវត្តន៍ និង និន្នាការនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍តំបន់ និង សកល ដែលមានសមានគតិភាពជាមួយនឹងស្ថានភាពកម្ពុជា ។ ក្នុងន័យនេះ, គោលនយោបាយនេះបានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង **"អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និង ផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គ សំដៅរួមចំណែកជំរុញសម្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជាដ៏រស់រវើក"** ដោយឈរលើមូលដ្ឋាននៃគោលការណ៍ចំនួន ៣ គឺ (១)-ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, (២)-ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង (៣)-ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ។

គោលនយោបាយនេះ មានគោលបំណង "អភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក តាមរយៈការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រកទទួលសេវាហិរញ្ញវត្ថុ, ភាពជឿទុកចិត្ត និង គុណភាពជីវិតរបស់អ្នកប្រើប្រាស់ ក្នុងយុគសម័យឌីជីថល" ។ គោលបំណងនេះ អាចសម្រេចបានដោយការអនុវត្តវិធានការគោលនយោបាយទៅតាមគោលដៅចម្បងចំនួន ៤ គឺ (១)-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយ-ផល, (២)-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, (៣)-ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និង (៤)-ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ វិធានការគោលនយោបាយសរុបទាំង ៥២ ត្រូវបានដាក់ចេញ ដើម្បីសម្រេចបានគោលដៅខាងលើ ។ ការអនុវត្តគោលនយោបាយនេះឈរលើយន្តការស្ថាប័នដែលមានស្រាប់ក្នុងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន ។ ស្ថាប័នទទួលបន្ទុកអនុវត្តទាំងនោះត្រូវរៀបចំផែនការសកម្មភាព, អនុវត្តសកម្មភាព និង រៀបចំរបាយការណ៍សមិទ្ធកម្មជាទៀងទាត់ ។ ក្នុងនោះ, គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ជាស្ថាប័នសម្របសម្រួល, ជំរុញ, ដឹកនាំ, តាមដាន និង វាយតម្លៃការអនុវត្តគោល-នយោបាយនេះ ។

ការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយនេះ នឹងធ្វើឱ្យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាកាន់តែមានភាពរីកចម្រើន ដែលនឹងស្តែងឱ្យឃើញតាមរយៈភាពរស់រវើកនៃប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការកើនឡើងនៃបរិយាបន្នហិរញ្ញវត្ថុ, ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុ, ការជឿទុកចិត្ត និង ការកាត់បន្ថយហានិភ័យនានា ដែលបណ្តាលមកពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ភាពរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជានឹងរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ប្រកបដោយចីរភាព បរិយាបន្នភាពធន់នឹងវិបត្តិ និង សមធម៌ ។

# ឧបសម្ព័ន្ធ ១. តារាងវិធានការគោលនយោបាយ

**កំណត់ចំណាំ៖** រយៈពេលខ្លី (ក្រោម ២ ឆ្នាំ) និង រយៈពេលមធ្យម (២-៥ ឆ្នាំ)

| ល.រ. | វិធានការគោលនយោបាយ | ស្ថាប័នទទួលបន្ទុក | ក្របខណ្ឌពេលវេលា |
|---|---|---|---|
| | **I. ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល** | | |
| ១ | ពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តក្របខណ្ឌបទប្បញ្ញត្តិសម្រាប់ការការពារទិន្នន័យ និង ការចែករំលែកទិន្នន័យក្នុងវិស័យហិរញ្ញវត្ថុ | - ធនាគារជាតិនៃកម្ពុជា<br>- និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ២ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំ និង ការដាក់ឱ្យប្រើប្រាស់ ឬ អនុវត្តក្របខណ្ឌគាំទ្រអភិបាលកិច្ចសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interfaces – APIs) និង អន្តរប្រតិបត្តិការ ព្រមទាំងអន្តរតំណភាពរវាងតួអង្គពាក់ព័ន្ធក្នុងឧស្សាហកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសរវាងនិយ័តករ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |

| | | | |
|---|---|---|---|
| ៣ | ប្រយុទ្ធនឹងបទល្មើសហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម និង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | - ធនាគារជាតិនៃកម្ពុជា<br>- និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៤ | ពិនិត្យលទ្ធភាពក្នុងការដាក់ចេញក្របខណ្ឌធនាគារបើកចំហ (Open Banking Framwork) | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៥ | ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និង/ឬ ពហុភាគីជាមួយនឹងប្រទេសក្នុងតំបន់ ដើម្បីគាំទ្រដល់ការទូទាត់សងប្រាក់ ឬ ការផ្ទេរប្រាក់ឆ្លងដែន | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៦ | កែសម្រួល ឬ ធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួនក្នុងវិស័យហិរញ្ញវត្ថុដែលអាចរាំងស្ទះ ឬ បង្កើតភាពស្មុគស្មាញដល់ការអភិវឌ្ឍ និង នវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ៧ | រៀបចំ, កែសម្រួល ឬ ធ្វើវិសោធនកម្មបទប្បញ្ញត្តិប្រុងប្រយ័ត្ន (Prudential Regulations) ដែលអនុវត្តចំពោះបច្ចេកវិទ្យាហិរញ្ញវត្ថុតាមការចាំបាច់ និង ចូលរួមលើកកម្ពស់ការការពារសន្តិសុខបច្ចេកវិទ្យាព័ត៌មានក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |

| | | | |
|---|---|---|---|
| ៨ | រៀបចំក្របខណ្ឌ ឬ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការវាយតម្លៃ និង ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Risk Assessment and Management) | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ៩ | គាំទ្រ និង ជំរុញការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ ជាពិសេសសន្តិសុខឌីជីថល ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីគតិយុត្ត ឬ ប្រព័ន្ធអេកូឡូស៊ីនិយ័តកម្ម សំដៅលើកកម្ពស់ភាពជឿទុកចិត្តលើបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១០ | សិក្សា និង រៀបចំយន្តការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ រួមទាំងកិច្ចការពារទិន្នន័យ និង ឯកជនភាព | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១១ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំ, ការដាក់ឱ្យដំណើរការ និង ការអភិវឌ្ឍបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងតាមដានជាប្រចាំនូវប្រតិបត្តិការរបស់បុគ្គលចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធការគ្រប់គ្រងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុជាមួយនឹងនិយ័តករបរទេស | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |

| | | | |
|---|---|---|---|
| ១២ | រៀបចំផែនការមេកសាងសមត្ថភាព និង ជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុដល់គ្រប់តួអង្គពាក់ព័ន្ធ ជាពិសេសសមត្ថភាពស្ថាប័នទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ១៣ | កសាងបណ្ដាញទំនាក់ទំនងជាមួយនឹងវិស័យឯកជន ដែលធ្វើកិច្ចប្រតិបត្តិការបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការចូលរួមពីវិស័យឯកជនក្នុងភាពជាដៃគូល្អនៃការកសាង និង ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាព | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១៤ | កសាងបណ្ដាញទំនាក់ទំនងជាមួយនឹងនិយ័តករហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនអន្តរជាតិនានា ដែលធ្វើប្រតិបត្តិការបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីសិក្សា, ស្វែងយល់ និង ជំរុញឱ្យមានការផ្លាស់ប្តូរមតិយោបល់ ក៏ដូចជាការចែករំលែកចំណេះដឹង, បទពិសោធ និង ឧត្តមានុវត្តន៍ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១៥ | រៀបចំ, កែសម្រួល និង ជំរុញការអនុវត្តផែនការអភិវឌ្ឍស្ថាប័នរបស់និយ័តករ និង អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយរំលេចឱ្យឃើញពីការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |
| ១៦ | រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បន្ទាប់ពីគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី |

| | | | |
|---|---|---|---|
| ១៧ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយធ្វើសុខដុមនីយកម្មមុខងារបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការបែងចែកមុខងាររវាងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឱ្យបានច្បាស់លាស់ និង មិនធ្វើឱ្យមានបម្រែបម្រួលជារចនាសម្ព័ន្ធដល់ស្ថាប័នដែលមានស្រាប់, ការកំណត់ប្រភេទបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ និង ធានានិយ័តភាពសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារក្នុងទីផ្សារ ព្រមទាំងកំណត់អំពីគោលការណ៍និយ័តកម្ម និង ត្រួតពិនិត្យសំខាន់ៗពាក់ព័ន្ធផ្សេងទៀត | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |
| ១៨ | រៀបចំយន្តការសហការ, សម្របសម្រួល និង ធ្វើកិច្ចសហប្រតិបត្តិការផ្ទៃក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារជាមួយនឹងធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនសហថាមពល, សហនវានុវត្តន៍, សហការទទួលខុសត្រូវ, សិនិទ្ធភាព និង សុខដុមនីយកម្មមុខងារនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១៩ | រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ និង ការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល និង បទប្បញ្ញត្តិគ្រប់គ្រងប្រតិបត្តិការហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល | - និយ័តករមូលបត្រកម្ពុជា | រយៈពេលខ្លី និង មធ្យម |
| **II. ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ** | | | |
| ១ | អភិវឌ្ឍ និង ដាក់ឱ្យប្រើប្រាស់ថ្នាលអត្តសញ្ញាណកម្មឌីជីថលសម្រាប់វិស័យហិរញ្ញវត្ថុ | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |

| | | | |
|---|---|---|---|
| ២ | ជំរុញការស្រាវជ្រាវ, ការសាកល្បង និង ការប្រើប្រាស់ថ្នាលឌីជីថលគ្រឹះដែលមានស្រាប់ ព្រមទាំងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះផ្សេងទៀតសម្រាប់ហិរញ្ញវត្ថុវិមជ្ឈការ | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |
| ៣ | អភិវឌ្ឍ និង ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីគាំទ្រដល់សេវា និង លើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់សងប្រាក់ឌីជីថល | - ធនាគារជាតិនៃកម្ពុជា | ជាប្រចាំ |
| ៤ | រៀបចំក្របខណ្ឌនិយ័តកម្ម និង ការត្រួតពិនិត្យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលរួមបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យានិយ័តកម្ម ដើម្បីជួយ និង ពង្រឹងអនុលោមភាពនិយ័តកម្មឱ្យកាន់តែមានប្រសិទ្ធភាពជាងសមត្ថភាពដែលមានស្រាប់ និង បច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីជួយដល់ការធ្វើឌីជីតូបនីយកម្មការរាយការណ៍ និង ដំណើរការនិយ័តកម្ម (Digitization of Reporting and Regulatory Processes) ដែលសំដៅគាំទ្រដំណើរការនៃការត្រួតពិនិត្យហានិភ័យ និង អនុលោមភាពប្រកបដោយបុរេសកម្មភាព និង ប្រសិទ្ធភាព | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |
| ៥ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការចែករំលែកនិងការបើកចំហទិន្នន័យដើម្បីផ្តល់កាលានុវត្តភាពថ្មីៗដល់ការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |

| | | | |
|---|---|---|---|
| ៦ | ជំរុញការប្រើប្រាស់ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលដែលមានស្រាប់ ដូចជា ថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា សម្រាប់ធ្វើយថាភូតកម្ម, ផ្ទៀងផ្ទាត់ និង ប្រើប្រាស់ទិន្នន័យអត្តសញ្ញាណសម្គាល់អតិថិជនឌីជីថល ដើម្បីលើកកម្ពស់គុណភាព, ភាពជឿទុកចិត្ត, ប្រសិទ្ធភាព និង សក្តិសិទ្ធិភាពនៃការផ្តល់, ការទទួលបាន និង ការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ៧ | ជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថល ដើម្បីលើកកម្ពស់សុវត្ថិភាព និង ប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ៨ | ជំរុញការប្រើប្រាស់ថ្នាល verify.gov.kh ដើម្បីផ្ទៀងផ្ទាត់និងបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារឌីជីថលដែលបានចេញដោយក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល | - ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៩ | ពង្រឹង និង ពង្រីកការប្រើប្រាស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុឌីជីថល ឱ្យក្លាយទៅជាប្រព័ន្ធមួយដែលមានចរិតលក្ខណៈអន្តរក្រសួង-ស្ថាប័ន ឈរលើគោលការណ៍ "ធ្វើតែមួយលើកគត់" (The Once-only Principle) | - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |

| | | | |
|---|---|---|---|
| ១០ | រៀបចំកម្មវិធីលើកកម្ពស់ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ ដែលគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការចាប់យក, ការប្រើប្រាស់, ការកែសម្រប, នវានុវត្តន៍ និង ការធ្វើពិពិធកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ១១ | ជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការរៀបចំ និង ការធ្វើទំនើបកម្មស្ថាប័ន ដូចជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាល, ប្រព័ន្ធចុះបញ្ជី, ប្រព័ន្ធ ឬ ថ្នាលប្រមូល និង គ្រប់គ្រងទិន្នន័យ, ប្រព័ន្ធវិភាគ និង ផ្តល់សញ្ញាមុន, ថ្នាលផ្តល់សេវាសាធារណៈ និង ថ្នាលផ្សេងៗ ទៀត | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១២ | ស្រាវជ្រាវអំពីហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ (Data Infrastructures) គាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| **III. ការជំរុញការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ** | | | |
| ១ | រៀបចំវេទិកាសាធារណៈ, ព្រឹត្តិការណ៍, កម្មវិធីប្រកួតប្រជែង, កម្មវិធីពិព័រណ៍ ឬ យុទ្ធនាការផ្សេងៗ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍ ក៏ដូចជាកាលានុវត្តភាពនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយសហការ, សម្របសម្រួល និង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងតួអង្គពាក់ព័ន្ធតាមការចាំបាច់ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |

| | | | |
|---|---|---|---|
| ២ | សហការជាមួយនឹងគ្រប់តួអង្គសង្គមពាក់ព័ន្ធ ដើម្បីដាក់ចេញកម្មវិធីស្ដីពីអក្ខរកម្មហិរញ្ញវត្ថុ, អក្ខរកម្មឌីជីថល និង ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដល់សាធារណជនទូទៅ និង សហគ្រិន | - ធនាគារជាតិនៃកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ជាប្រចាំ |
| ៣ | រៀបចំផតថលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Portal) ដើម្បីចែកចាយ និង ចែករំលែកទិន្នន័យ, ព័ត៌មាន, ឯកសារ និង ចំណេះដឹងផ្សេងៗ សំដៅគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាព | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៤ | ជំរុញការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាគាំទ្រគន្លឹះៗ ដូចជា បញ្ញាសិប្បនិម្មិត (Artificial Intelligence – AI), ម៉ាស៊ីនស្វ័យសិក្សា (Machine Learning – ML), ទិន្នន័យធំ, បច្ចេកវិទ្យាក្លោដ (Cloud Computing), បច្ចេកវិទ្យាប្លុកឆេន (Blockchain Technology), កិច្ចសន្យាឆ្លាត (Smart Contract), បច្ចេកវិទ្យាប្រព្រឹត្តិកម្មភាសាធម្មជាតិ (Natural Language Processing – NLP), បច្ចេកវិទ្យាតថភាពនិម្មិត (Virtual Reality Technology) និង បច្ចេកវិទ្យាវិភាគទិន្នន័យ ដើម្បីជំរុញនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៥ | ជំរុញ និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាដល់ធុរជន, សហគ្រិន និង សាធារណជន ដើម្បីផ្លាស់ប្តូរឥរិយាបថ និង លើកកម្ពស់ភាពជឿទុកចិត្តលើបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |

| | | | |
|---|---|---|---|
| ៦ | ជំរុញ និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាដល់ថ្នាក់ដឹកនាំ និង មន្ត្រី ដើម្បីកសាង និង អភិវឌ្ឍភាពជាអ្នកដឹកនាំ និង សមត្ថភាពពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៧ | រៀបចំថ្នាលលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីបង្កើត, រក្សាទុក, ផ្ទេរ ឬ ចែករំលែកចំណេះដឹងបច្ចេកវិទ្យាឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៨ | ជំរុញឱ្យមានការរៀបចំកម្មវិធីបណ្តុះបណ្តាល និង លើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសិក្សា, អប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេល មធ្យម (ជាប្រចាំ) |
| ៩ | រៀបចំ និង ធ្វើបច្ចុប្បន្នកម្មសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Lexicon) ដើម្បីលើកកម្ពស់អក្ខរកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលខ្លី និង មធ្យម |
| ១០ | លើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ និង នវានុវត្តន៍បច្ចេកវិទ្យា ដែលគាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមបញ្ចូលចាប់ពីកម្រិតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ | - ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |

| | | | |
|---|---|---|---|
| ១១ | អភិវឌ្ឍ និងអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ១ ២ ៣ ៤ លើជំនាញឌីជីថលសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងលើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេស | - ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ១២ | សិក្សាសមិទ្ធិលទ្ធភាពក្នុងការរៀបចំឱ្យមានប្រព័ន្ធគាំពារសុខុមាលភាពអតិថិជន តួយ៉ាង ការថែទាំ និង ការគាំទ្រអតិថិជន និង ការដោះស្រាយបណ្តឹង ដោយប្រើប្រាស់បច្ចេកវិទ្យា | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| | **IV. ការជំរុញការអភិវឌ្ឍ និង នវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ** | | |
| ១ | ដាក់ចេញបទប្បញ្ញត្តិ និង គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការផ្តល់ប្រាក់កម្ចីឌីជីថល ប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ២ | ពង្រឹងក្របខណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន និង យន្តការសុវត្ថិភាពក្នុងប្រតិបត្តិការទូទាត់សងប្រាក់ឌីជីថល | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៣ | លើកកម្ពស់ការប្រើប្រាស់មធ្យោបាយទូទាត់សងប្រាក់ឌីជីថលជាមួយនឹងវិស័យសាធារណៈ និង វិស័យឯកជន | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៤ | លើកកម្ពស់ផលិតផល និង សេវាធនាគារឌីជីថលប្រកបដោយនវានុវត្តន៍ | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៥ | ជំរុញគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុឱ្យដាក់ប្រើប្រាស់នូវការផ្តល់ប្រាក់កម្ចី ឬ សន្សំប្រាក់ឌីជីថល | - ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |

| | | | |
|---|---|---|---|
| ៦ | ជំរុញការអភិវឌ្ឍ និង ការប្រើប្រាស់ផលិតផល និង សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុ និង កម្មវិធីវិមជ្ឈការ (Decentralized Application – dApp) ដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ | រយៈពេលមធ្យម |
| ៧ | ជំរុញឱ្យមានការលើកទឹកចិត្តសារពើពន្ធ, ការគាំទ្រផ្នែកហិរញ្ញវត្ថុ និង ការគាំទ្រផ្សេងទៀតដល់សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម |
| ៨ | លើកកម្ពស់ការស្រាវជ្រាវ និង ការអភិវឌ្ឍ ដើម្បីបង្កើននវានុវត្តន៍សេវា និង ផលិតផល និងធ្វើពិពិធកម្មសកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |
| ៩ | លើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការរៀបចំវេទិកា, សិក្ខាសាលា និង កម្មវិធីផ្សេងៗ រួមទាំងកម្មវិធីបណ្តុះ និង ពន្លឿនធុរកិច្ចថ្មីបច្ចេកវិទ្យាហិរញ្ញវត្ថុ | - និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>- មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី និង មធ្យម (ជាប្រចាំ) |

## ឧបសម្ព័ន្ធ ២. សទ្ទានុក្រម

| ល.រ. | ភាសាខ្មែរ | ភាសាអង់គ្លេស | និយមន័យ |
|---|---|---|---|
| ១ | កម្មវិធីវិមជ្ឈការ | Decentralized Application ( dApp ) | កម្មវិធីដែលធ្វើប្រតិបត្តិការដោយប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន និង កិច្ចសន្យាឆ្លាត។ |
| ២ | ការជួញដូរវិក្កយបត្រ | Invoice Trading | សកម្មភាពរបស់ក្រុមហ៊ុនក្នុងការខ្ចីប្រាក់ពីវិនិយោគិនតាមរយៈវិក្កយបត្រដែលពុំទាន់បានទូទាត់ ឬ វិក្កយបត្រដែលផុតកាលបរិច្ឆេទសម្រាប់ទូទាត់ ។ |
| ៣ | ការផ្តល់ប្រាក់កម្ចីដែលមានភាពប្រថុយប្រថាន | Predatory Lending Practices | ការដាក់លក្ខខណ្ឌសម្រាប់ផ្តល់ប្រាក់កម្ចី ដែលមិនស្មើភាព, បោកបញ្ឆោត ឬ រំលោភបំពានដល់អ្នកខ្ចី រួមមានដូចជា ការយកថ្លៃសេវាផ្តល់ប្រាក់កម្ចី ឬ ការប្រាក់ខ្ពស់ ឬ ការផ្តល់ប្រាក់កម្ចីដែលមានអត្រាឥណទានទាបដល់អ្នកខ្ចីដែលមានពិន្ទុឥណទានខ្ពស់។ |
| ៤ | កិច្ចសន្យាឆ្លាត | Smart Contract | កូដដែលដំណើរការលើប្លុកឆេន ដើម្បីត្រួតពិនិត្យ, ប្រតិបត្តិ និង អនុវត្តកិច្ចសន្យា ឬ កិច្ចព្រមព្រៀងគតិយុត្ត ប្រកបដោយភាពជឿទុកចិត្ត ដោយមិនមានការចូលរួមពីតតិយភាគី ។ |
| ៥ | អក្ខរកម្មហិរញ្ញវត្ថុ | Financial Literacy | សមត្ថភាពក្នុងការយល់ និង ការប្រើប្រាស់ជំនាញហិរញ្ញវត្ថុផ្សេងៗ រួមមានដូចជា ការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និង ការវិនិយោគ ប្រកបដោយប្រសិទ្ធភាព ។ |
| ៦ | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា | Cambodia Data Exchange ( CamDX ) | ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល សម្រាប់ផ្លាស់ប្តូរទិន្នន័យ ដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានា និង រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជន ដោយសុវត្ថិភាព និងដោយយន្តការច្បាស់លាស់តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬ បណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ។ |

| | | | |
|---|---|---|---|
| ៧ | ទិន្នន័យធំ | Big Data | បណ្តុំទិន្នន័យដែលមានទំហំធំ មានច្រើនសណ្ឋាន និង ជាទូទៅ គ្មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយត្រូវបានប្រើប្រាស់ដើម្បីវិភាគរកលំនាំ, និន្នាការ និង ការជាប់ទាក់ទងគ្នារវាងដែនមួយនិងដែនមួយទៀត។ |
| ៨ | ទ្រព្យឌីជីថល | Digital Asset | ឯកតាឌីជីថលមានតម្លៃ ដែលត្រូវបានបង្កើតឡើងនៅលើបច្ចេកវិទ្យាឌីអិលធី ឬ បច្ចេកវិទ្យាស្រដៀងគ្នា ឬ មានភ្ជាប់នូវកិច្ចសន្យាឆ្លាត ឬ កិច្ចសន្យាក្នុងទម្រង់ផ្សេងរវាងអ្នកកាន់កាប់ទ្រព្យឌីជីថល និង សមភាគី និង ដែលអាចជួញដូរ ឬ ផ្ទេរបាន រួមបញ្ចូលទាំងប៊ីតខ័ញ (Bitcoin) ។ ទ្រព្យឌីជីថលទាំងនេះជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។ |
| ៩ | ធុរកិច្ចថ្មី | Startups | ស្ថាប័ន ឬ ដំណើរការបង្កើត និង គ្រប់គ្រងធុរកិច្ចដែលប្រើប្រាស់នវានុវត្តន៍ជាស្នូលនៃការបង្កើតគំរូអាជីវកម្មរបស់ខ្លួន ក្រោមលក្ខខណ្ឌមិនច្បាស់លាស់ និង មានហានិភ័យ ប៉ុន្តែមានសក្តានុពលរីកចម្រើនលឿន ។ |
| ១០ | បច្ចេកវិទ្យាក្លោដ | Cloud Computing Technology | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១១ | បច្ចេកវិទ្យាត្រួតពិនិត្យ | Supervisory Technology (SupTech) | បច្ចេកវិទ្យាហិរញ្ញវត្ថុដែលគាំទ្រ និង ជួយសម្រួលដល់និយ័តករ និង អង្គភាពត្រួតពិនិត្យ ក្នុងការធ្វើឌីជីតូបនីយកម្មដំណើរការនៃការរាយការណ៍ និង និយ័តកម្ម សំដៅពង្រឹងប្រសិទ្ធភាព និង សក្តិសិទ្ធិភាពនៃការគ្រប់គ្រង និង ការត្រួតពិនិត្យហានិភ័យ និង អនុលោមភាពរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ។ |
| ១២ | បច្ចេកវិទ្យានិយ័តកម្ម | Regulatory Technology (RegTech) | បច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលជួយសម្រួល, ពង្រឹង និង ធ្វើស្វ័យប្រវត្តិកម្មអនុលោមភាព ឬ លក្ខខណ្ឌតម្រូវនិយ័តកម្ម ក្នុងឧស្សាហកម្មហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាពជាងសមត្ថភាពដែលមានស្រាប់ ។ |

| | | | |
|---|---|---|---|
| ១៣ | បច្ចេកវិទ្យាប្លុកឆេន | Blockchain Technology | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យ ជាខ្សែប្រវាក់ដែលមិនត្រូវការការកែប្រែ ហើយទិន្នន័យទាំងនោះនឹងត្រូវចម្លងដើម្បីផ្ទុកនៅតាមបណ្ដាសេវូបករណ៍ ដែលចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យនេះក្នុងទម្រង់បែបវិមជ្ឈការ ។ |
| ១៤ | បច្ចេកវិទ្យាហិរញ្ញវត្ថុ | Financial Technology (FinTech) | បច្ចេកវិទ្យា និង នវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុ ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បង្កើតឡើងដើម្បីឱ្យមានការប្រើប្រាស់ ផ្ដល់ និង ទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយ ប្រកបដោយបរិយាបន្នកម្ម ។ |
| ១៥ | បញ្ញាសិប្បនិម្មិត | Artificial Intelligence (AI) | បច្ចេកវិទ្យាដែលអនុញ្ញាតឱ្យម៉ាស៊ីនកុំព្យូទ័រមានសមត្ថភាពរៀន, គិត, វិភាគ និង យល់ដឹងពីបញ្ហាជាក់លាក់ណាមួយ ដោយយកលំនាំតាមសមត្ថភាពខួរក្បាលមនុស្ស ។ |
| ១៦ | បទប្បញ្ញត្តិប្រុងប្រយ័ត្ន | Prudential Regulations | បទប្បញ្ញត្តិដែលផ្ដោតលើការរក្សាសុវត្ថិភាព និង ស្ថិរភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុ ។ |
| ១៧ | បរិយាបន្នហិរញ្ញវត្ថុ | Financial Inclusion | លទ្ធភាពដែលប្រជាពលរដ្ឋគ្រប់រូបទទួលបាន និង ប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ។ |
| ១៨ | បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ | FinTech Regulatory Sandbox | បរិស្ថានសម្រាប់ឱ្យគ្រឹះស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុសាកល្បងនូវសេវា និង ផលិតផលរបស់ខ្លួន ជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងទំហំ និង រយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និង ការជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ។ |
| ១៩ | ប្រព័ន្ធបាគង | Bakong | ប្រព័ន្ធទូទាត់សងប្រាក់កន្លោងដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងផ្ដល់លទ្ធភាពទូទាត់ឆ្លងគ្រឹះស្ថាន, បង្កើនប្រសិទ្ធភាពប្រតិបត្តិការទូទាត់, ជំរុញបរិយាបន្នហិរញ្ញវត្ថុ និង លើកកម្ពស់ការទូទាត់ជាប្រាក់រៀល ។ |

| | | | |
|---|---|---|---|
| ២០ | ភាពលំអៀងនៃក្បួនដោះស្រាយ | Algorithmic Bias | កំហុសជាប្រព័ន្ធ និង កើតឡើងដដែលៗនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដែលបង្កើតជាលទ្ធផលមិនស្មើភាព ។ ឧទាហរណ៍៖ "ការផ្ដល់បុព្វសិទ្ធិ" ឱ្យដល់ក្រុមមួយជាងក្រុមមួយផ្សេងទៀត ដែលខុសពីមុខងារដែលបានគ្រោងទុកនៃក្បួនដោះស្រាយ ។ |
| ២១ | ម៉ាស៊ីនស្វ័យសិក្សា | Machine Learning ( ML ) | បច្ចេកវិទ្យាមួយនៃបញ្ញាសិប្បនិម្មិត ដែលផ្តល់សមត្ថភាពឱ្យម៉ាស៊ីនក្នុងការសិក្សា ការទទួលស្គាល់ និង ការព្យាករលទ្ធផល ឬ សមិទ្ធកម្មបានកាន់តែត្រឹមត្រូវ និង ល្អប្រសើរ ប្រកបដោយស្វ័យភាព ដោយផ្អែកលើទិន្នន័យដែលត្រូវធ្វើប្រព្រឹត្តិកម្ម ដោយមិនចាំបាច់មានការធ្វើកម្មវិធីនីយកម្មច្បាស់លាស់ដើម្បីធ្វើដូច្នោះឡើយ ។ |
| ២២ | សន្តិសុខសាយប័រ | Cybersecurity | ការអនុវត្តនៃការទប់ស្កាត់, ការឆ្លើយតប និង ការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធ, បណ្តាញ, ប្រព័ន្ធប្រតិបត្តិការ និង កម្មវិធី ពីការជ្រៀតចូល និង ការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ២៣ | សន្ទនីយភាព | Liquidity | កម្រិតដែលទ្រព្យសកម្ម ឬ សញ្ញាបណ្ណ អាចត្រូវបានទិញ ឬ លក់នៅក្នុងទីផ្សារ ដោយពុំមានការប៉ះពាល់ដល់តម្លៃទ្រព្យសកម្មនោះ ។ សន្ទនីយភាពឆ្លុះបញ្ចាំងពីសមត្ថភាពក្នុងការបម្លែងទ្រព្យសកម្មមួយឱ្យទៅជាសាច់ប្រាក់ ។ |
| ២៤ | សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ | Application Programming Interfaces ( APIs ) | ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬ ច្រើន ។ |
| ២៥ | សមាមាត្រភាព | Proportionality | លក្ខណៈសមាមាត្រនៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលលក្ខខណ្ឌតម្រូវនិយ័តកម្ម ( Regulatory Requirements ) ឆ្លើយតបទៅនឹងទំហំអាជីវកម្ម, សារៈសំខាន់ជាប្រព័ន្ធ និង កម្រិតហានិភ័យ ។ |

| | | | |
|---|---|---|---|
| ២៦ | សេវាធនាគារចល័ត | Mobile Banking | ការធ្វើប្រតិបត្តិការធនាគារ និង ហិរញ្ញវត្ថុ តាមរយៈកម្មវិធីរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដោយប្រើប្រាស់ឧបករណ៍ចល័ត រួមមានដូចជា ទូរសព្ទចល័ត និង ថេប្លេត ជាដើម ។ |
| ២៧ | សេវាធនាគារបើកចំហ | Open Banking | ការអនុវត្តរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និង គ្រឹះស្ថានមិនមែនធនាគារ និង ហិរញ្ញវត្ថុ ដែលផ្តល់ឱ្យអ្នកដំណើរការតតិយភាគីនូវការប្រើប្រាស់ទិន្នន័យរបស់អតិថិជន រួមមានដូចជា ទិន្នន័យទាក់ទងនឹងការធ្វើប្រតិបត្តិការ ជាដើម តាមរយៈការប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ។ |
| ២៨ | ស្តង់ដាខេអេចយូអរ | KHQR | ប្រព័ន្ធយូអរកូតដែលបង្កើតឡើងសម្រាប់ការទូទាត់លក់រាយក្នុងប្រទេស និង ការទូទាត់ឆ្លងដែន។ |
| ២៩ | ហត្ថលេខាឌីជីថល | Digital Signature | ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់កំណត់អត្តសញ្ញាណរបស់ហត្ថលេខី រួមមាន ហត្ថលេខាអេឡិចត្រូនិក, ហត្ថលេខាជីវមាត្រ និង ហត្ថលេខាផ្សេងៗ ។ |
| ៣០ | ហិរញ្ញប្បទានពីបុគ្គលទៅបុគ្គល | Peer-to-peer (P2P) Financing | ថ្នាលឌីជីថលសម្រាប់បុគ្គលផ្តល់ហិរញ្ញប្បទានដល់បុគ្គលដទៃ ។ |
| ៣១ | ហិរញ្ញវត្ថុវិមជ្ឈការ | Decentralized Finance (DeFi) | ប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យមានការជួញដូរទ្រព្យឌីជីថល ផ្អែកលើបច្ចេកវិទ្យាប្លុកឆេនដោយមិនមានអន្តរការិយកម្ម ។ |
| ៣២ | អក្ខរកម្មឌីជីថល | Digital Literacy | ជំនាញដែលជំរុញសមត្ថភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍សម្រាប់ការសិក្សា រៀនសូត្រ, កម្សាន្ត, ការងារ និង ការប្រាស្រ័យទាក់ទង ។ |

| | | | |
|---|---|---|---|
| ៣៣ | អាជីវកម្មក្រោដហ្វាន់ឌីង | Crowdfunding | ប្រតិបត្តិការប្រមូលមូលនិធិ តាមរយៈគម្រោងនៃការវិនិយោគរួម ឬ អន្តរការិយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិរវាងបុគ្គលធ្វើសំណើលក់មូលបត្រ និង វិនិយោគិន ។ |

# គោលនយោបាយ
# អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា
# ២០២៣ - ២០២៨